

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

# ផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រ ក្នុងវិស័យព័ត៌មាន

## រយៈពេល ៥ ឆ្នាំ ២០០៦-២០១០

រៀបចំដោយក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន
ដោយសហការជាមួយគំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រ
នៃក្រសួងកិច្ចការនារី និង កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ

ឆ្នាំ ២០០៦

UNDP

ក្រសួងកិច្ចការនារី

ក្រសួងពត៌មាន
MINISTRY OF INFORMATION

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យព័ត៌មាន

## រយៈពេល ៥ ឆ្នាំ ២០០៦-២០១០

រៀបចំដោយក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន

ដោយសហការជាមួយ គំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រនៃក្រសួងកិច្ចការនារី

និង កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ

ឆ្នាំ ២០០៦

# មាតិកា


បុព្វកថា ........................................................ ៣

សេចក្តីថ្លែងអំណរគុណ ........................................................ ៥

**ជំពូកទី ១: ស្ថានភាពស្ត្រីនៅកម្ពុជា** ........................................................ ៧

១.១ តើយេនឌ័រមានអត្ថន័យដូចម្តេច? ........................................................ ៧

១.២ ស្ត្រី និង បរិបទសង្គម ........................................................ ៨

១.៣ ស្ត្រី និង អំពើហិង្សា ........................................................ ៨

១.៤ ស្ត្រី និង ការសិក្សាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ........................................................ ៩

១.៥ ស្ត្រី និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ........................................................ ៩

១.៦ ស្ត្រី និង ការទទួលសេវាសុខាភិបាល ........................................................ ៩

**ជំពូកទី ២: ស្ថានភាពស្ត្រីក្នុងវិស័យព័ត៌មាន** ........................................................ ១១

២.១ ស្ថានភាពស្ត្រី និង ប្រព័ន្ធឃោសនានៅកម្ពុជា ........................................................ ១១

២.២ តំណែងបុរស និង ស្ត្រីនៅក្នុងថ្នាក់ដឹកនាំនៃក្រសួងព័ត៌មាន ........................................................ ១៣

២.៣ ផែនការសកម្មភាពនៃក្រសួងព័ត៌មាន ........................................................ ១៥

២.៤ ធនធានមនុស្ស និង ការបណ្តុះបណ្តាលបុគ្គលិកនៃក្រសួងព័ត៌មាន ........................................................ ១៥

២.៥ សកម្មភាពនៃវិស័យព័ត៌មានទាក់ទងនឹងយេនឌ័រ ........................................................ ១៨

២.៦ ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន ........................................................ ១៨

**ជំពូកទី ៣: យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររយៈពេល៥ ឆ្នាំ ២០០៦-២០១០** .............. ១៩

៣.១ សេចក្តីថ្លែងការណ៍អំពីយុទ្ធសាស្ត្រ ........................................................ ១៩

៣.២ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររយៈពេល ៥ឆ្នាំ ២០០៦-២០១០ ........................................................ ១៩

**ជំពូកទី ៤: ការសន្និដ្ឋាន** ........................................................ ២៧

**ឧបសម្ព័ន្ធ:** ........................................................ ២៨

ក. តារាងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មាន, ២០០៦-២០១០ ........................................................ ២៩

ខ. ឯកសារយោង ........................................................ ៣៣

គ. សមាជិកភាពក្រុមបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន ........................................................ ៣៤

# បុព្វកថា

ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលអាណត្តិទី៣ នៃរដ្ឋសភា និងបណ្តាប្រទេសដែលជាដៃគូអភិវឌ្ឍន៍បានចាត់ទុកការលើកកំពស់សមភាពយេនឌ័រជាផ្នែកដ៏សំខាន់មួយ ដែលពុំអាចខ្វះបាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។ ក្នុងការលើកកំពស់សមភាព យេនឌ័រ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្តេជ្ញាចិត្ត និងផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយគំលាតយេនឌ័រក្នុងវិស័យព័ត៌មាន សុខាភិបាល អប់រំ កសិកម្ម សេដ្ឋកិច្ច ទីផ្សារការងារ ការសំរេចចិត្ត និងឋានានុក្រមក្នុងសង្គមដើម្បីអោយស្ត្រីមានលទ្ធភាព កាន់តែច្រើនក្នុង ការទទួលសេវា និងផលប្រយោជន៍ផ្សេងៗ ដែលមានក្នុងសង្គម និងបង្កើនការចូលរួមរបស់ស្ត្រី និងកុមារ ក្នុងការអភិវឌ្ឍន៍ស្ថាប័នគ្រប់កំរិត។

ក្រសួងព័ត៌មាន មានបេសកកម្មចំបងក្នុងការផ្តល់ព័ត៌មាន ផ្តល់ចំណេះដឹង និងការអប់រំ និងផ្តល់ការកំសាន្តសប្បាយដោយអនុវត្តទិសស្លោក ***ម្ចាស់ ស្មើរ ឆន្ទមិន្តសារ*** ជូនប្រជាជនកម្ពុជាទាំងពីរភេទដោយស្មើភាព និងធានាថាស្ត្រី និងបុរស បានទទួលសេវាព័ត៌មាន និងផលប្រយោជន៍ផ្សេងៗក្នុងវិស័យព័ត៌មានស្មើៗគ្នា។ បេសកកម្មនេះ អាចសំរេចបានជោគជ័យកាន់តែប្រសើរឡើង ប្រសិនបើគំលាតយេនឌ័រ នៅក្នុងវិស័យដែលបានរៀបរាប់ខាងលើត្រូវបានកាត់បន្ថយឬលុបបំបាត់។ ទិន្នន័យមួយចំនួនបានបង្ហាញអំពីគំលាត រវាងមន្ត្រីព័ត៌មានជាស្ត្រី និងបុរសនៅក្នុងផ្នែកបណ្តុះបណ្តាលមូលដ្ឋាន ការបណ្តុះបណ្តាលបន្តទាំងក្នុង និង ក្រៅប្រទេស ធនធានមនុស្ស ឋានៈ តំណែងទាក់ទងនឹងការធ្វើសេចក្តីសំរេចចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់ដល់ថ្នាក់ការិយាល័យស្រុក។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងព័ត៌មាន ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល រួមទាំងផ្នែកឯកជនផង បានបង្កើនសេវាផ្សព្វផ្សាយព័ត៌មាន ប៉ុន្តែដោយកង្វះខាតទិន្នន័យព័ត៌មានដែលមានការបែងចែកតាមភេទ ក្នុងការទទួលសេវាព័ត៌មាន ធ្វើអោយគេពុំដឹងថាតើបុរស និង ស្ត្រីទទួលបានផលប្រយោជន៍ពីសមិទ្ធផលនេះក្នុងកំរិតណា។ យោងតាមការវិភាគលើផែនការសកម្មភាពនៃក្រសួងព័ត៌មាន បានបង្ហាញថា ក្រសួងព័ត៌មាន និងស្ថាប័នពាក់ព័ន្ធគប្បីបង្កើនការ ផ្សព្វផ្សាយព័ត៌មាន និង សារអំពីយេនឌ័រអោយកាន់តែទូលំទូលាយថែមទៀតជូន ដល់ប្រជាពលរដ្ឋទូទាំងប្រទេស។

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យព័ត៌មាននេះ មានគោលបំណងចំបងក្នុងការកាត់បន្ថយគំលាតរវាងបុរសនិងស្ត្រីក្នុងវិស័យព័ត៌មាន និងបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រទៅក្នុងសង្គមកម្ពុជាដើម្បីចូលរួមលើកកំពស់សិទ្ធិមនុស្ស និងកាត់បន្ថយ ភាពក្រីក្រនៅប្រទេសកម្ពុជា។ ការអនុវត្តនៃផែនការយុទ្ធសាស្ត្រនេះ អាចសំរេចបានដោយជោគជ័យ អាស្រ័យលើការគាំទ្រ ការចូលរួម និងកិច្ចសហការពីគ្រប់ស្ថាប័នជាតិ-អន្តរជាតិ និងប្រជាជននៅគ្រប់ជាន់ថ្នាក់។ ៘

ភ្នំពេញ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦

**រដ្ឋមន្ត្រី ក្រសួងព័ត៌មាន**

ខៀវ កាញារីទ្ធ

# សេចក្តីថ្លែងអំណរគុណ

ឯកសារស្តីពីផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យព័ត៌មានត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន ដោយសហការជាមួយគំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* របស់ក្រសួងកិច្ចការនារី ក្រោមការឧបត្ថម្ភនៃកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ។ ក្រុមអ្នករៀបចំឯកសារនេះ សូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះអស់លោក និងលោកស្រី ដែលជាមន្ត្រីរាជការនិងមិត្តរួមការងារ ចំពោះការផ្តល់ជាយោបល់ ទស្សនៈ ការចំណាយពេលវេលាដើម្បីធ្វើការរៀបចំកែសំរួល និងការផ្តល់ជាអនុសាសន៍ ដ៏មានសារៈសំខាន់ ក្នុងការចងក្រងជាឯកសារនេះ។

ជាបឋមយើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តម **ខៀវ កាញារិទ្ធ** រដ្ឋមន្ត្រី និងឯកឧត្តម **ថាច់ ផែន** រដ្ឋលេខាធិកាក្រសួងព័ត៌មានដែលគាំទ្រ និងលើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះដំណើរការរៀបចំបង្កើតក្រុមការងារបច្ចេកទេសយេនឌ័ររបស់ក្រសួងព័ត៌មាន និង ការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

ឯកសារនៃផែនការយុទ្ធសាស្ត្រយេនឌ័រនៅក្នុងក្រសួងព័ត៌មានបានរៀបចំចងក្រងឡើង ដោយមានការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីគំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* របស់ក្រសួងកិច្ចការនារីនិងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ។ ហេតុនេះហើយយើងខ្ញុំជាសមាជិកក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងព័ត៌មានសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះការគាំទ្រកិច្ចសហការ និង ចំពោះការផ្តល់យោបល់ដ៏ថ្លៃថ្លា របស់លោកស្រី ញាណ សុចិត្រា ប្រធានគំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* នៃក្រសួងកិច្ចការនារី និងបណ្ឌិតទីប្រឹក្សាថ្នាក់ជាតិរបស់គំរោងនេះ។

ជាទីបញ្ចប់ក្រុមការងារបច្ចេកទេសយេនឌ័រសូមថ្លែងនូវសេចក្តីអំណរគុណជាអនេកប្បការចំពោះ លោកស្រី Elaine Mckay ដែលជាទីប្រឹក្សាជាន់ខ្ពស់របស់គំរោង*ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* ចំពោះការផ្តួចផ្តើមការណែនាំ ការផ្តល់ជាយោបល់ ការចំណាយពេលវេលា និងការគាំទ្រដ៏សស្រាក់សស្រាំ និងអស់ពីចិត្តពីថ្លើមក្នុងដំណើរការរៀបចំ ផែនការយុទ្ធសាស្ត្រនេះ និងក្នុងការលើកកំពស់សមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា។

ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន

# ជំពូកទី ១
# ស្ថានភាពស្ត្រីនៅប្រទេសកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទីបីផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់របស់ស្ត្រី ដោយចាត់ទុកថាស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ។ ការយកចិត្តទុកដាក់ក្នុងការលើកកំពស់យេនឌ័រត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលស្របនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍សកល និងសំរាប់ប្រទេសកម្ពុជា។ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយគំលាតរវាងបុរស និងស្ត្រីធ្វើអោយស្ត្រីមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលសេវា និង ផលប្រយោជន៍ផ្សេងៗ ដែលមានក្នុងសង្គម និងបង្កើនការចូលរួមរបស់ស្ត្រី និងកុមារីក្នុងការអភិវឌ្ឍន៍ស្ថាប័នគ្រប់កំរិត ។

ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណនេះ ក្រសួងកិច្ចការនារីបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ *នារីរតនៈ* ២០០៤-២០០៨ ក្នុងគោលបំណងលើកកំពស់ស្ថានភាពស្ត្រីទាំងក្នុងផ្នែករដ្ឋ និងឯកជន។ ដោយសារហេតុផលនេះ ក្រសួងកិច្ចការនារីសហការជាមួយបណ្តាក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រយៈពេល ៥ ឆ្នាំ ២០០៦-២០១០ និងទៅក្នុងគោលនយោបាយ កម្មវិធី និង សកម្មភាពនានា នៅក្នុងសង្គម ដើម្បីអោយស្ត្រី និងបុរសទទួលបានផលប្រយោជន៍ស្មើគ្នាដូចបុរស ។

## ១.១ អត្ថន័យនៃពាក្យយេនឌ័រ

យេនឌ័រជាពាក្យថ្មីសំរាប់ប្រជាជនកម្ពុជាទូទៅ ដោយពាក្យនេះត្រូវបានគេទទួលដឹងឮជាបន្តបន្ទាប់ចាប់តាំងពីដើមទសវត្សទី៩០ ដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានឆ្លុះបញ្ចាំងពីសមភាពយេនឌ័រ ហើយប្រទេសកម្ពុជាជាហត្ថលេខីនៃកិច្ចព្រមព្រៀងមួយចំនួន និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ យេនឌ័រត្រូវបានគេកំណត់ថាជាទំនាក់ទំនងរវាងបុរស និងស្ត្រីនៅក្នុងគ្រួសារ និងសង្គមទាំងមូល ដែលពាក់ព័ន្ធនឹងការបែងចែកសិទ្ធិអំណាច ឋានៈតួនាទី ការងារពលកម្ម និងការទទួលផលប្រយោជន៍ដែលសង្គមបានកំណត់ឡើង ហើយសង្គមក៏ជាអ្នកកែប្រែផងដែរ (European Commission 2004) ។

បច្ចុប្បន្ននេះស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជាមានកំរិតទាប ធៀបជាមួយបណ្តាប្រទេសនានាលើពិភពលោក ដោយកម្ពុជាមានចំណាត់ថ្នាក់ទី១០៥ ក្នុងចំនោមប្រទេសចំនួន១៤៤ (UNIFEM et al. ២០០៤) ។ សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ[១] របស់កម្ពុជាគឺ ០. ៥៥៧ ដែលជាកំរិតទាបបំផុតនៅអាស៊ី នេះបញ្ជាក់ពីវិសមភាពយេនឌ័រនៅ ប្រទេសកម្ពុជា (UNDP ២០០៤)។ សន្ទស្សន៍នេះប្រហាក់ប្រហែលនឹងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស[២] (០. ៥៦៨) ដែលមានន័យថាស្ត្រីកម្ពុជាមានអាយុ

[១] សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (gender development index) ជារង្វាស់ស្ទង់ពីវិសមភាពយេនឌ័រ ( UNIFEM et al. 2004 ) ។

[២] សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (human development index) ជារង្វាស់ស្ទង់ការអភិវឌ្ឍន៍មនុស្សនៅក្នុងប្រទេស ។ សន្ទស្សន៍នេះជារង្វាស់រួមមួយស្តីពីអាយុកាល ការអប់រំ និង កំរិតជីវភាពរស់នៅ ( UNIFEM et al. 2004 ) ។

កាលសង្ឃឹមរស់ខ្លី ក៏រិតអក្ខរភាពទាប និង មានកំរិតជីវភាពក្រខ្សត់។ ទន្ទឹមនឹងនេះរង្វាស់សិទ្ធិអំណាចយេនឌ័រ[៣] នៅប្រទេសកម្ពុជាមានកំរិតទាបនៅអាស៊ីគឺ ០.២៨៣ ដែលមានន័យថា ស្ត្រីកម្ពុជាមានចំនួនតិចតួចមានតំណែងធ្វើសេចក្តីសំរេចដោយស្ត្រីមានតំណាងរបស់ខ្លួនតិចបំផុតនៅក្នុងជួរថ្នាក់ដឹកនាំ និង នៅក្នុងតំណែងមុខវិជ្ជាជីវៈ (UNIFEM et al. ២០០៤)។ តួលេខទាំងនេះបានបញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជា និងបណ្តាភាគីអភិវឌ្ឍន៍ទាំងឡាយត្រូវផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើវិស័យនេះ។

## ១,២ ស្ត្រី និងបរិបទសង្គម

សង្គមកម្ពុជាត្រូវបានគេចាត់ទុកថាជាសង្គមមាតាធិបតេយ្យ ដែលស្ត្រីហាក់ដូចជាមានតួនាទីដ៏សំខាន់នៅក្នុងគ្រួសារ និងសង្គមដូចជាព្រះនាងសោម ម៉ា និងព្រះនាងឥន្ទ្រទេវីក្នុងយុគសម័យអង្គរដ៏រុងរឿង។ ក្រោយពីការធ្លាក់ចុះក្រោយសម័យអង្គរ និងដោយសារសង្គ្រាមវិបត្តិសង្គម ភាពក្រីក្រ និងអំពើហិង្សានៅកម្ពុជាបានបំផ្លិចបំផ្លាញគ្រួសារ និងស្ត្រីកម្ពុជា។ ជាបន្ថែមវិបត្តិទាំងនេះបានធ្វើអោយតំលៃសីលធម៌ ការគោរពចំពោះស្ត្រី និងសិទ្ធិរបស់ស្ត្រីធ្លាក់ចុះ។ សព្វថ្ងៃនេះមេគ្រួសារដែលជាស្ត្រីមេម៉ាយដោយសារវិបត្តិទាំងនេះមានចំនួន ១ ភាគ ៤ នៃគ្រួសារកម្ពុជាទាំងអស់ ហើយភាគច្រើននៃក្រុមគ្រួសារទាំងនេះក្រីក្រជាងគេ។ លក្ខខ័ណ្ឌអវិជ្ជមានមួយទៀតដែលកើតឡើងដោយសារវិបត្តិទាំងនេះ ហើយបានក្លាយជាវិបត្តិចំពោះការអភិវឌ្ឍន៍ប្រទេសជាតិគឺលំដាប់ឋានានុក្រម នៃសង្គមដែលជានិមិត្តរូបនៃអំណាចនិងឋានៈនៅក្នុងសង្គម។ នៅក្នុងសង្គមកម្ពុជាស្ត្រីហាក់ដូចជាត្រូវបានគេចាត់ទុកថាមានឋានៈទាបជាងបុរស (UNIFEM et al. 2004)។

## ១,៣ ស្ត្រី និងអំពើហិង្សា

ការប៉ាន់ប្រមាណអំពីយេនឌ័រនៅប្រទេសកម្ពុជា (UNIFEM et al. 2004) បានបង្ហាញថាមានការកើនឡើងនូវ អំពើហិង្សាទាក់ទងនិងយេនឌ័រ ដូចជាអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និងការជួញដូរស្ត្រី និងកុមារ។ យោងតាមការអង្កេតនាពេលថ្មីៗនេះ បានបង្ហាញថាស្ត្រីចំនួន ២២.៥ ភាគរយនៃស្ត្រីដែលបានចូលរួមក្នុងការសំភាសន៍បាននិយាយថាខ្លួនបានទទួលអំពើហិង្សាពីប្តីរបស់ខ្លួន ហើយបុរសចំនួន ១២.៥ ភាគរយបានរាយការណ៍ថាខ្លួនបានទទួលអំពើហិង្សាពីប្រពន្ធ (Cambodia, Ministry of Women's Affairs et al. 2005) ហើយអំពើហិង្សានេះ បានបណ្តាលអោយមានផលប៉ះពាល់អវិជ្ជមានលើគ្រួសារទាំងផ្នែកសេដ្ឋកិច្ច រាងកាយ ផ្លូវចិត្ត សុខភាព និងការសិក្សារបស់កូនក្នុងបន្ទុក។ ដោយយល់ឃើញថាការបំបាត់អំពើហិង្សា និងការភ័យខ្លាចនៅក្នុងគ្រួសារ និងសង្គមមានសារសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍ប្រទេស និងសង្គមកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅឆ្នាំ ២០០៥ សំរាប់ដោះស្រាយបញ្ហាទាំងនេះ។ ការអនុវត្តន៍ច្បាប់នៅប្រទេសកម្ពុជាបានជួបប្រទះការលំបាក និងនៅទន់ខ្សោយ។ ដើម្បីចូលរួមកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ក្រសួងព័ត៌មានមានតួនាទីសំខាន់ ក្នុងការផ្សព្វផ្សាយសារដើម្បីលើកកំពស់សីលធម៌ សុជីវធម៌ និង តំលៃនៃការគោរពស្រឡាញ់រវាងបុរស និងស្ត្រីក្នុងគ្រួសារ និង សង្គម និង អត្ថន័យនៃច្បាប់ប្រឆាំងនឹងអំពើហិង្សា។

[៣] រង្វាស់សិទ្ធិអំណាចយេនឌ័រ (gender empowerment measure) ជារង្វាស់ស្ទង់ការចូលរួមរបស់នារីធៀបនឹងបុរសនៅក្នុងសកម្មភាព នយោបាយ និងសេដ្ឋកិច្ច។

## ១,៤ ស្ត្រី និងការសិក្សាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ

នៅក្នុងវិស័យអប់រំ អត្រាអនក្ខរភាពចំពោះស្ត្រីមានចំនួនខ្ពស់ជាងបុរស ។ ស្ត្រីចំនួន ៤៥ ភាគរយមិនចេះអាន និងមិនចេះសរសេរសោះធៀបនឹងបុរសដែលមានចំនួនតែ ២៥ ភាគរយ ។ ហើយស្ត្រីចេះអាននិងសរសេរតិចតួចមានចំនួនច្រើនជាងបុរស ពោលគឺមានស្ត្រីចំនួន ៧១ ភាគរយ ធៀបនឹងបុរសដែលមានចំនួនតែ ៥០ ភាគរយ ។ ចំពោះការបណ្តុះបណ្តាលទូទៅគំលាតរវាងសិស្សស្រី និងសិស្សប្រុសបានកើនឡើងយ៉ាងខ្លាំងនៅពេលសិស្សទាំងនេះសិក្សាកាន់តែខ្ពស់ ។ ការចុះឈ្មោះចូលរៀននៅថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សារវាងសិស្សស្រី និងសិស្សប្រុសមានចំនួនប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែចំនួនសិស្សស្រីនៅថ្នាក់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិមានចំនួនតិចជាងសិស្សប្រុស គឺសិស្សស្រីនៅថ្នាក់មធ្យមសិក្សាបឋមភូមិ មានចំនួន ៦៣ នាក់ ធៀបនឹងសិស្សប្រុស ១០០ នាក់ ហើយនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ មានសិស្សស្រីចំនួនតែ ៥០ នាក់ ប៉ុណ្ណោះធៀបនឹងសិស្សប្រុស ១០០ នាក់ ។ កង្វះការអប់រំមូលដ្ឋាននេះធ្វើអោយស្ត្រីមានឱកាស និងសមត្ថភាពតិចជាងបុរសនៅក្នុងការទទួលការងារដែលមានប្រាក់កំរៃខ្ពស់ (UNIFEM et al. 2004) ។ ក្រសួងព័ត៌មានមានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយកម្មវិធីលើកកំពស់ចំណេះដឹងនានាដើម្បីបង្កើនចំណេះដឹងដល់សាធារណជនជាពិសេសសំរាប់ស្ត្រី ។

## ១, ៥ ស្ត្រីនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម

វិសមភាពយេនឌ័រកំពុងរាលដាលនៅក្នុងទីផ្សារពលកម្មនៅប្រទេសកម្ពុជា ។ ឥរិយាបទជាប្រពៃណីនៅលើការបែងចែកតួនាទីបុរស និងស្ត្រីបានធ្វើអោយវិសមភាពយេនឌ័រនេះមានការកើនឡើង ជាពិសេសគំលាតយេនឌ័រនៅក្នុងវិស័យការងារ ។ ការអង្កេតនៅប្រទេសកម្ពុជានៅឆ្នាំ ២០០១ បានបង្ហាញថាមានស្ត្រី ៨២ ភាគរយ ចូលរួមក្នុងកំលាំងពលកម្ម ដែលជាអត្រាខ្ពស់ជាងគេនៅអាស៊ី ហើយមានស្ត្រីចំនួន ៥២ ភាគរយចូលរួមក្នុងកំលាំងពលកម្មសកម្ម ។ ទោះបីជាមានការវិនិយោគលើវិស័យកាត់ដេរដែលបានស្រូបកំលាំងពលកម្មស្ត្រីច្រើនជាងបុរស ក៏ស្ត្រីក្នុងកំលាំងពលកម្មសកម្មប្រហែល ៥៣ ភាគរយ ធ្វើការក្នុងគ្រួសារដែលជាការងារគ្មានប្រាក់កំរៃដែលជាមូលហេតុអាចអោយស្ត្រីពុំមានប្រាក់កាស និងមិនមានលទ្ធភាពក្នុងការទទួលសេវាសុខាភិបាល ការអប់រំ និង ចូលរួមក្នុងសកម្មភាពនានា និងជួបការលំបាកក្នុងការប្រកួតប្រជែងរកការងារមានប្រាក់កំរៃខ្ពស់ជាមួយបុរស (UNIFEM et al. 2004) ។ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងផ្សារការងារក្រសួងព័ត៌មានអាចចូលរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានអំពីការងារដែលមានក្នុងសង្គម ។

## ១,៦ ស្ត្រី និងការទទួលសេវាសុខាភិបាល

បច្ចុប្បន្ននេះស្ត្រីកម្ពុជាមានអាយុកាលសង្ឃឹមរស់ទាប ហើយអត្រាមរណភាពមាតាមានកំរិតខ្ពស់ជាងគេនៅអាស៊ីគឺ ៤៣៧ នាក់ ក្នុងចំណោម ១០០.០០០ នៃកំណើតរស់ (CDHS 2000). តួលេខនេះឆ្លុះបញ្ចាំងថា សុខភាពមាតាស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ ។ អត្រាមរណៈភាពដ៏ខ្ពស់នេះអាចបណ្តាលមកពីស្ត្រីមិនបានទទួលគ្រប់គ្រាន់នូវសេវាសុខាភិបាល និងទទួលពត៌មានអំពីការថែទាំសុខភាព ។ កត្តាផ្សេងទៀតដែលរារាំងស្ត្រីមិនឱ្យទទួលបានសេវាសុខភាពមានដូចជាផ្ទះមានចំងាយឆ្ងាយពីមន្ទីរពេទ្យ និងតំលៃធ្វើដំណើរខ្ពស់ កំរិតវប្បធម៌ទាប និងភាពក្រីក្រ ។ លើសពីនេះទៀត ទំនៀមទំលាប់ទាក់ទងទៅនឹងការមានផ្ទៃពោះ ការសំរាលកូន និង ការថែទាំទារកបានរារាំងស្ត្រីមិនអោយទទួលបានសេវាសុខាភិបាលសមស្របពេលមានផ្ទៃពោះ

នៅពេលសំរាល និងក្រោយពេលសំរាលកូន ។ ក្រសួងព័ត៌មានមានតួនាទីសំខាន់ក្នុងការលើកកំពស់សុខភាពប្រជាជនទាំងពីរភេទ តាមរយៈការផ្សព្វផ្សាយសារ និងកម្មវិធីអប់រំសុខភាព និងសេវាសុខាភិបាលនានា ។

## សេចក្តីសន្និដ្ឋាន

យោងតាមទិន្នន័យខាងលើនេះបានបង្ហាញថា ស្ត្រីដែលមានចំនួន ៥២ ភាគរយ នៃចំនួនប្រជាជនសរុបនៅប្រទេសកម្ពុជា កំពុងស្ថិតក្នុងស្ថានភាពពិបាកជាងបុរសនៅក្នុងវិស័យសំខាន់ៗដូចជា ការអប់រំ សុខាភិបាល ទីផ្សារ ពលកម្ម តួនាទីជាថ្នាក់ដឹកនាំ និងឋានានុក្រមនៅក្នុងសង្គម ដូច្នេះ វាជាការចាំបាច់ណាស់ដែលបណ្តាស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ត្រូវយកចិត្តទុកដាក់លើគំលាតរវាងស្ត្រី និងបុរសដែលមាននៅក្នុងសង្គម ។

# ឧបសម្ព័ន្ធទី ២

# ស្ថានភាពស្ត្រីក្នុងវិស័យព័ត៌មាន

## ២.១ ស្ថានភាពស្ត្រី និងប្រព័ន្ធឃោសនានៅកម្ពុជា

### តារាងទី ១: ស្ថានីយ៍វិទ្យុ ទូរទស្សន៍ខ្សែកាបនៅប្រទេសកម្ពុជា ពីឆ្នាំ ១៩៩៩-២០០៥

| រាជធានីភ្នំពេញ | | | | | | | |
|---|---|---|---|---|---|---|---|
| **មធ្យោបាយផ្សព្វផ្សាយ** | **១៩៩៩** | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** |
| ទូរទស្សន៍រដ្ឋ | ១ | ១ | ១ | ១ | ១ | ១ | ១ |
| ទូរទស្សន៍ឯកជនចំរុះរដ្ឋ | ២ | ២ | ២ | ២ | ២ | ២ | ២ |
| ទូរទស្សន៍ឯកជន | ៣ | ៣ | ៣ | ៣ | ៤ | ៤ | ៤ |
| ទូរទស្សន៍ខ្សែកាប | ៣ | ៣ | ៣ | ៣ | ៣ | ៤ | ៤ |
| វិទ្យុរដ្ឋ | ២ | ២ | ២ | ២ | ២ | ២ | ២ |
| វិទ្យុឯកជនចំរុះរដ្ឋ | ៣ | ៣ | ៣ | ៣ | ៤ | ៤ | ៤ |
| វិទ្យុឯកជន | ៨ | ៨ | ៨ | ៨ | ៩ | ៩ | ៩ |
| **បណ្តាខេត្ត-ក្រុង** | | | | | | | |
| ខេត្តមានទូរទស្សន៍រដ្ឋ | ៣ | ៤ | ៤ | ៤ | ៧ | ៧ | ៧ |
| ខេត្តមានទូរទស្សន៍ឯកជនចំរុះរដ្ឋផ្សាយបន្តពីភ្នំពេញ | ១ | ១ | ១ | ១ | ៧ | ៧ | ៧ |
| ខេត្តទូរទស្សន៍ឯកជនផ្សាយបន្តពីភ្នំពេញ | ០ | ១ | ១ | ១ | ២ | ១០ | ១៥ |
| ស្ថានីយ៍ទូរទស្សន៍ខ្សែកាប | ៩ | ១១ | ១៤ | ១៨ | ៣៧ | ៤២ | ៤៥ |
| ខេត្តមានវិទ្យុរដ្ឋ | ៤ | ៤ | ៤ | ៤ | ៨ | ៧ | ៨ |
| វិទ្យុឯកជនចំរុះរដ្ឋផ្សាយពីភ្នំពេញ | ០ | ០ | ០ | ០ | ៤ | ៦ | ៩ |
| វិទ្យុឯកជនផ្សាយពីភ្នំពេញ | ០ | ១ | ៣ | ៣ | ៤ | ៤ | ៦ |
| **សារព័ត៌មានបោះពុម្ព** | | | | | | | |
| ព្រឹត្តិប័ត្រ AKP (រដ្ឋ) | ១ | ១ | ១ | ១ | ១ | ១ | ១ |
| ទស្សនាវដ្តីកម្ពុជា (រដ្ឋ) | ១ | ១ | ១ | ១ | ១ | ១ | ១ |
| Website AKP | ១ | ១ | ១ | ១ | ១ | ១ | ១ |
| កាសែតឯកជន | ១៤០ | ១៦៦ | ១៩១ | ២០៥ | ២៤៨ | ២៥២ | ២៥០ |
| ព្រឹត្តិប័ត្ររបស់អង្គការសង្គមស៊ីវិល | | | | | | | ២៩ |
| ទស្សនាវដ្តីឯកជន និង អង្គការសង្គមស៊ីវិល | | | | | | | ៨៥ |

*ប្រភព: សន្និបាតក្រសួងព័ត៌មាន, ឆ្នាំ ២០០៦ក*

បណ្តាញឃោសនាមានតាមរយៈវិទ្យុទូរទស្សន៍,សារព័ត៌មាននិងតាមមធ្យោបាយផ្សេងៗ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការផ្សព្វផ្សាយព័ត៌មានដូចជាសមភាពរវាងប្រជាពលរដ្ឋទាំងពីរភេទក្នុងការសំរេចការទទួលសេវា និងការទទួលផលប្រយោជន៍ផ្សេងៗដែលមាននៅក្នុងសង្គម ។ សេវាព័ត៌មាន ជាពិសេសក្រសួងព័ត៌មានមានតួនាទី ២ ដ៏សំខាន់ៈ ទីមួយគឺ ក្នុងការផ្តល់ព័ត៌មានល្អៗអំពីសុខភាព ការអប់រំ ការងារ និងសិទ្ធិរបស់ស្ត្រីតាមរយៈបណ្តាសកម្មភាព ដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ ២០០៦-២០១០ និងទី២គឺ ការបង្កើនចំនួនមន្ត្រីជាស្ត្រី និងតំណែងដែលមានការសំរេចចិត្តដល់មន្ត្រីជាស្ត្រីនៅក្រសួងព័ត៌មានតាមគ្រប់លំដាប់ថ្នាក់ ។ សេវាព័ត៌មាននៅប្រទេសកម្ពុជារួមមាន ទូរទស្សន៍ វិទ្យុ និង សំភារៈបោះពុម្ពរបស់រដ្ឋ រដ្ឋចំរុះ ឯកជន និង សេវាឯកជននៅរាជធានីភ្នំពេញ និងបណ្តាខេត្តក្រុង ។

ការអង្កេតខ្នាតមធ្យមដែលធ្វើឡើងដោយមណ្ឌលព័ត៌មានស្ត្រីកម្ពុជានៅឆ្នាំ ២០០៥ បានបង្ហាញថាស្ត្រីមានចំនួនតិចតួចប្រៀបធៀបនឹងបុរសបំរើការនៅក្នុងវិស័យព័ត៌មានទាំងផ្នែករដ្ឋនិងឯកជន ដែលនៅក្នុងនោះមានស្ត្រីចំនួន ១៧ ភាគរយបំរើការងារជាអ្នកសារព័ត៌មាន (ចាងហ្វាង, អ្នកនិពន្ធ, អ្នកយកព័ត៌មាន, ពិធីករ និង ផលិតករ) ២១ ភាគរយបំរើការជាអ្នកបច្ចេកទេស និងការី (កាន់កាមេរ៉ា, វិទ្យុ និង ឧបករណ៍ផ្សេងៗ) និង ២៨ ភាគរយ ជាបុគ្គលិករដ្ឋបាល (បុគ្គលិករដ្ឋបាល និងគណនេយ្យ) ។ ភាគច្រើននៃស្ត្រីដែលបំរើការនៅក្នុងវិស័យព័ត៌មានមានសញ្ញាប័ត្រទុតិយភូមិ ។

**ក្រាហ្វិកទី១: ការទស្សនាកម្មវិធីទូរទស្សន៍ដោយស្ត្រី និង បុរស**




*(ប្រភពៈ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ២០០៥)*

សំគាល់: ១: ព័ត៌មាន ២: កាភ៌អ្វូនេ ៣: ភាពយន្ត ៤: រឿងភាគ ៥: ការប្រគុំតន្ត្រី ៦: ដំណឹងកីឡា ៧: រឿងកំប្លែង ៨: ប្រដាល់ ៩: កម្មវិធីអប់រំ ១០: កម្មវិធីស្ត្រីដើម្បីស្ត្រី ១១: សុខភាពស្ត្រី ១២: ផ្សេងៗ

ប្រជាជនកម្ពុជាភាគច្រើនបានទទួលសេវាព័ត៌មានរបស់រដ្ឋ និងឯកជនដែលរួមការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ សារព័ត៌មាន និងទស្សនាវដ្តីផ្សេងៗ ។ ការអង្កេតដោយមណ្ឌលព័ត៌មានស្ត្រីកម្ពុជានៅឆ្នាំ ២០០៥ បានបង្ហាញថាមានប្រជាជនភាគច្រើន (៦៩ ភាគរយ) ទស្សនាទូរទស្សន៍រយៈពេលពី ១ ទៅ ៣ ម៉ោងរៀងរាល់ថ្ងៃ ។ កម្មវិធីទូរទស្សន៍ដែលទាំងបុរស និង

ស្ត្រីចូលចិត្តទស្សនាជាងគេគឺកម្មវិធីព័ត៌មាន ( ៨៥ ភាគរយ) រឿងភាគ ( ៧១ ភាគរយ) និងចំរៀងការ៉ាអូខេ ( ២៣ ភាគរយ) ។ ប៉ុន្តែគេពុំមានទិន្នន័យចំនួនព័ត៌មានដែលនិយាយអំពីស្ត្រី នៅក្នុងប្រព័ន្ធឃោសនាទាំងរបស់រដ្ឋ និងឯកជន ។

ប្រជាជនចំនួន ៤៧ ភាគរយស្តាប់វិទ្យុរយៈពេលពី ១ ទៅ ៣ ម៉ោងរាល់ថ្ងៃ ប៉ុន្តែមានប្រជាជនជាង ៣៧ ភាគរយ មិនស្តាប់វិទ្យុ ។ មានប្រជាជនភាគច្រើនមិនអានសារព័ត៌មានដោយសារការពិបាកក្នុងការជាវតំលៃខ្ពស់ ភាពមមាញឹកក្នុងការងារ និងកំរិតអនក្ខរភាពទាប ជាពិសេសនៅតាមទីជនបទ ។ មានប្រជាជនតែ ១០ ភាគរយ ប៉ុណ្ណោះអានសារព័ត៌មាន រាល់ថ្ងៃ និង ៤៤ ភាគរយអានមួយដងក្នុងមួយសប្តាហ៍ ។ ទិន្នន័យទាំងនេះសំដៅលើទាំង បុរស និងស្ត្រី ហើយគេពុំអាចទទួលបានទិន្នន័យដែលមានការបែងចែកតាមភេទឡើយ ។

ការតាមដានកម្មវិធីផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាបានបង្ហាញថាកម្មវិធីអំពីស្ត្រីមានចំនួនតិចតួច ។ កម្មវិធីវិទ្យុមាន កម្មវិធីអំពីស្ត្រីច្រើនជាងគេគឺ ៣៥ ភាគរយ បន្តដោយកម្មវិធីទូរទស្សន៍មាន ១៥ ភាគរយ ហើយសារព័ត៌មានមានអត្ថបទអំពីស្ត្រីតិចជាងគេគឺ ១២ ភាគរយ ។ នៅក្នុងកម្មវិធីអំពីស្ត្រីទាំងនោះភាគច្រើនបង្ហាញថាស្ត្រី ជាជនរងគ្រោះនៃអំពើហិង្សាជាភស្តុតាងថាការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារជាអំពើខុសច្បាប់ ( ៥៨ ភាគរយ) តួនាទីសំខាន់របស់ស្ត្រីនៅក្នុងសង្គម ( ២៧ ភាគរយ) និងជាគោលដៅនៃការរួមភេទ ( ២២ ភាគរយ)( មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ២០០៥) ។ ដូច្នេះ ការបង្កើនកម្មវិធីអំពីស្ត្រីតាមប្រព័ន្ធឃោសនាមានសារសំខាន់បំផុត ដោយបង្ហាញពីតួនាទីសំខាន់របស់ស្ត្រីសង្គមជោគជ័យរបស់ស្ត្រី ការលើកកំពស់ស្ត្រីដើម្បីទទួលបានការសិក្សា និងមានចូលរួមចំណែកស្មើគ្នាដូចបុរសក្នុងការអភិវឌ្ឍន៍ និងទទួលផលប្រយោជន៍ផ្សេងៗ ។

## ២.២ តំណែងបុរស និងស្ត្រីនៅក្នុងថ្នាក់ដឹកនាំនៃក្រសួងព័ត៌មាន

### ក្រាហ្វិកទី ២: តំណែងថ្នាក់ដឹកនាំរវាងបុរស និង ស្ត្រីនៅថ្នាក់កណ្តាលនៃក្រសួងព័ត៌មាន




*ប្រភព: ក្រសួងព័ត៌មាន, ឆ្នាំ ២០០៦ខ*

សំគាល់: ១: រដ្ឋមន្ត្រី, ២: រដ្ឋលេខា, ៣: អនុរដ្ឋលេខា, ៤: អគ្គនាយក, ៥: អគ្គនាយករង, ៦: ប្រធាននាយកដ្ឋាន, ៧: អនុប្រធាននាយកដ្ឋាន, ៨: ប្រធានការិយាល័យ ៩: អនុការិយាល័យ, ១០: សរុបមន្ត្រីទូទាំងប្រទេស

ក្រសួងព័ត៌មានមានបុគ្គលិកជាបុរសមានចំនួនច្រើនលើសលុបជាងបុគ្គលិកជាស្ត្រី ដោយក្នុងចំណោមបុគ្គលិកចំនួនបួនរូប មានស្ត្រីចំនួនមួយរូប (សូមមើលក្រាហ្វិក ២)។ ស្ត្រីដែលមានតំណែងជាថ្នាក់ដឹកនាំនៅក្នុងក្រសួងនេះកាន់តែមានចំនួនតិច ជាងបុគ្គលិកជាបុរសតាំងពីថ្នាក់ដឹកនាំថ្នាក់កណ្តាល និងនៅតាមខេត្តក្រុងគឺមានន័យថាបុគ្គលិកជាស្ត្រីកាន់តែមានចំនួនតិច កាលណាតំណែងកាន់តែខ្ពស់។ នៅក្រសួងព័ត៌មានពុំមានស្ត្រីណាម្នាក់មានតំណែងនៅក្នុងថ្នាក់ដឹកនាំជាសមាជិករដ្ឋាភិបាល។ មានស្ត្រីតែម្នាក់ប៉ុណ្ណោះមានឋានៈជាអគ្គនាយកក្នុងចំណោមអគ្គនាយកបួនរូប និងពីររូបមានឋានៈជាអគ្គនាយករងក្នុងចំណោម អគ្គនាយករង ២៨ រូប។ ចំនួននេះបានកើនឡើងបន្តិចបន្តួចចាប់ពីថ្នាក់នាយកដ្ឋាន និងការិយាល័យនៅថ្នាក់កណ្តាល។ មានស្ត្រីចំនួន តិចតួចធៀបនឹងមន្ត្រីជាបុរសមានតំណែងជាថ្នាក់ដឹកនាំនាយកដ្ឋាន (ស្ត្រី ២ រូប និងបុរស ២៤ រូបជា ប្រធាននាយកដ្ឋាន ហើយស្ត្រី ១៤ រូប និងបុរស ១៤៦ រូបជាអនុប្រធាននាយកដ្ឋាន)។ ចំនួនដែលមានតំណែងជាថ្នាក់ដឹកនាំនេះបានកើន ដល់ ១៣ ភាគរយ (ស្ត្រី១១ រូប, បុរស៧៤ រូប) និង ២៨ ភាគរយ (ស្ត្រី ៨៩ រូប, បុរស ២២៩ រូប) នៅថ្នាក់ការិយាល័យ និងអនុការិយាល័យ នៅថ្នាក់ជាតិ។ នៅក្រសួងព័ត៌មានមានមន្ត្រីជាស្ត្រីចំនួនមួយធៀបនឹងមន្ត្រីជាបុរសចំនួនបីរូប (ស្ត្រី ២៦, ៨ ភាគរយ ឬ ៥៥៧ រូប, បុរស ១៥២២ រូប)។

## ក្រាហ្វិកទី ៣: តំណែងថ្នាក់ដឹកនាំរវាងបុរស និង ស្ត្រីនៅថ្នាក់ខេត្ត-ក្រុង




*(ប្រភព: ក្រសួងព័ត៌មាន, ឆ្នាំ ២០០៦ខ)*

ក្រាហ្វិកទី៣បង្ហាញថាស្ត្រីកាន់តែមានតំណាងរបស់ខ្លួននៅក្នុងជួរថ្នាក់ដឹកនាំថ្នាក់ខេត្ត-ក្រុងតិចជាងតំណាងរបស់ខ្លួន នៅក្នុងថ្នាក់ដឹកនាំថ្នាក់កណ្តាលនៃក្រសួងព័ត៌មាន។ មានស្ត្រីមួយរូបមានតំណែងជាប្រធានមន្ទីរព័ត៌មានខេត្តកំពង់ចាម ហើយមាន ស្ត្រីតែ ៦ រូបធៀបនឹងបុរសចំនួន ៤៦ រូបមានតួនាទីជាអនុប្រធានមន្ទីរ។ ចំនួននេះបានកើនឡើងបន្តិចបន្តួចដល់ ៩.១ ភាគរយ (ស្ត្រី ៦ រូប ធៀបបុរស ៦០ រូប) និង ៧.៣ ភាគរយ (ស្ត្រី ៩ រូប ធៀបនឹងបុរស ១១៤ រូប) នៅថ្នាក់ប្រធានការិយាល័យខេត្ត-ក្រុង និងស្រុក។ ស្ត្រីមានតំណាងរបស់ខ្លួនច្រើននៅក្នុងថ្នាក់ដឹកនាំ ជាអនុប្រធានតាំងពីថ្នាក់មន្ទីរខេត្ត-ក្រុង, ការិយាល័យខេត្ត និង ស្រុក-ខ័ណ្ឌដែលឋានៈមានសិទ្ធិតិចតួចក្នុងការសំរេចចិត្តក្នុងអង្គភាព។ ក្នុងតំណែងជាអនុប្រធានការិយាល័យខេត្តមានបុគ្គលិកជា

ស្ត្រីចំនួន ៣០ ភាគរយ ធៀបនឹងបុរសចំនួន ៧០ ភាគរយ ( ស្ត្រី៣២ រូប ធៀបនឹងបុរស ៧៥ រូប) ហើយស្ត្រីមានចំនួន ២៣ ភាគរយ កាន់តំណែងជាអនុប្រធានការិយាល័យស្រុក ខ័ណ្ឌ ធៀបនឹងបុរសចំនួន ៧៧ ភាគរយ ( ស្ត្រីចំនួន ១៣ រូប បុរសចំនួន ៤៤ រូប) ។ វិសមភាពនៃតួនាទីជាថ្នាក់ដឹកនាំរវាងបុរសនិងស្ត្រីនៃក្រសួងព័ត៌មានអាចបណ្តាលអោយមានកង្វះការគិតគូរអំពីផលប្រយោជន៍ស្ត្រីនៅក្នុងការងារ និងក្នុងវិស័យព័ត៌មាន ។

## ២.៣ ផែនការសកម្មភាពនៃក្រសួងព័ត៌មាន

ការវិភាគទិសដៅការងារ និងសកម្មភាពរបស់ក្រសួងព័ត៌មានដែលបានអនុវត្តនាឆ្នាំ ២០០៤ បានបង្ហាញថា ក្រសួងព័ត៌មានបានខិតខំផ្សព្វផ្សាយព័ត៌មានតាមវិទ្យុទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មានអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ សកម្មភាពរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ ជាបន្ថែម ក្រសួងព័ត៌មានគោលបំណងបង្កើនការផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ និងជំរុញកម្មវិធីផ្សព្វផ្សាយអប់រំដល់សង្គមដើម្បីបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ។ ប៉ុន្តែរបាយការណ៍សកម្មភាពនិងសំណូមពរបង្កើនការផ្សព្វផ្សាយ និងបង្កើនចំណេះដឹងរបស់សង្គមដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពនៃក្រសួងព័ត៌មានឆ្នាំ ២០០៥ ហាក់ដូចជាមិនបានឆ្លុះបញ្ចាំងពីតំរូវការរបស់ស្ត្រី និងបុរសក្នុងការទទួលសេវាព័ត៌មាន និងប្រភេទព័ត៌មានសំរាប់បង្កើនស្ថានភាពសុខភាព សុខុមាលភាព សិទ្ធិ និងសុវត្ថិភាពសំរាប់ស្ត្រី ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ ២០០៦-២០១០ លើកឡើងពីការបង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាហាក់ដូចជាពុំបានលើកឡើងអំពីតំរូវការយេនឌ័រ ក្នុងវិស័យព័ត៌មាន ។ ជាបន្ថែមផែនការរយៈពេលបីឆ្នាំ ២០០៦-២០០៨ នៃក្រសួងព័ត៌មានក៏ពុំបានបញ្ជាក់ច្បាស់លាស់ពីតំរូវការយេនឌ័រ និងការទទួលបានផលប្រយោជន៍ ស្មើគ្នារវាងបុរស និងស្ត្រីពីការសេវាកម្មព័ត៌មាន ។

## ២.៤ ធនធានមនុស្ស និងការបណ្តុះបណ្តាលបុគ្គលិកនៃក្រសួងព័ត៌មាន

យោងតាមការវិភាគទិន្នន័យទទួលបានពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា អគ្គនាយកដ្ឋានវិទ្យុជាតិ អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍របស់ក្រសួងព័ត៌មាន គិតដល់ឆ្នាំ ២០០៦ បានបង្ហាញក្រសួងព័ត៌មានមានធនធានមនុស្សតិចតួច ប្រៀបធៀបនឹងក្រសួងផ្សេងៗ ដូចជា ក្រសួងសុខាភិបាល ( សូមមើលក្រាហ្វិក ៤) ។ ក្រសួងព័ត៌មានមានមន្ត្រីមានសញ្ញាប័ត្រអនុបណ្ឌិតចំនួន ១៣ រូប ( ០. ៦២ ភាគរយ) ដែលមានបុរស ១២ រូប និង ស្ត្រី ១ រូប ។ មានមន្ត្រីចំនួន ៩៨ រូប ( ៤,៧១ ភាគរយ) មានបរិញ្ញាប័ត្រដែលភាគច្រើនជាបុរស ( បុរសចំនួន ៨៦ រូប ប្រៀបធៀបនឹងស្ត្រីចំនួន ១២ រូប) ហើយមានមន្ត្រីមានវិញ្ញាបនប័ត្រវិជ្ជាជីវៈ ៥,៨ ភាគរយ ដែលក្នុងនោះមានស្ត្រីចំនួន ១០ រូបនិង បុរសចំនួន ៤៥ រូប ។ ភាគច្រើននៃមន្ត្រី ក្រសួងព័ត៌មានមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ២១,៣៥ ភាគរយភាគច្រើនជាបុរសចំនួន ៣៥០ រូបធៀបនឹងស្ត្រីចំនួន ៩៤ រូប ( សូមមើលក្រាហ្វិកទី ៥) ។ ទិន្នន័យនេះបង្ហាញថាមានគំលាតផ្នែកចំណេះដឹងបច្ចេកទេស និងការបណ្តុះបណ្តាលរវាងមន្ត្រីព័ត៌មានជាស្ត្រី និងបុរស ហើយក្រសួងព័ត៌មានត្រូវការការបណ្តុះបណ្តាលធនធាន មនុស្សទាំងផ្នែកបច្ចេកទេស និងការគ្រប់គ្រង ។ តាមរបាយការណ៍សកម្មភាពនៃក្រសួងព័ត៌មានឆ្នាំ ២០០៤ បានបង្ហាញថាក្រសួងព័ត៌មានបានទទួលជំនួយផ្នែកបច្ចេកទេស និងថវិកាតិចតួចពីបណ្តាដៃគូអភិវឌ្ឍន៍ និងស្ថាប័នផ្សេងៗ ដើម្បីបង្កើនសមត្ថភាពមន្ត្រីទាំង ២ ភេទទាំងផ្នែកគ្រប់គ្រង និងជំនាញបច្ចេកទេស ។

## ក្រាហ្វិកទី ៤: ធនធានមនុស្សនៅថ្នាក់កណ្តាលនៃក្រសួងព័ត៌មាន




*ប្រភព: ទិន្នន័យក្រសួងព័ត៌មាន, ឆ្នាំ ២០០៦ខ*

មន្ត្រីជាស្ត្រីនៅក្រសួងព័ត៌មានបានទទួលឱកាសតិចតួចក្នុងការទទួលបានបណ្តុះបណ្តាលទាំងរយៈពេលតិចជាងបីច្រើនជាងបីខែទាំងក្នុងនិងក្រៅប្រទេសធៀបនឹងមន្ត្រីជាបុរស ។ គិតមកដល់ឆ្នាំ ២០០៦ និងគិតជារួមមន្ត្រីជាស្ត្រីបានទទួលការបណ្តុះបណ្តាលចំនួន ២៩ ករណី ធៀបនឹងបុរសចំនួន ២៥០ ករណី ( ស្ត្រី ១១.៦ ភាគរយ បុរស ៨៨.១ ភាគរយ) ។ មន្ត្រីជាស្ត្រីបានទទួលការបណ្តុះបណ្តាលក្នុងស្រុករយៈពេលតិចជាងបីខែចំនួន៩ករណី ( ៦.៩ ភាគរយ) ធៀបនឹងមន្ត្រីជាបុរសទទួលបានចំនួន ១២២ ករណី ហើយទទួលការបណ្តុះបណ្តាលលើសពីបីខែ ចំនួន ១៥ ករណី (២៣.៤ ភាគរយ) ប្រៀបធៀបនឹងបុរសទទួលបានចំនួន ៤៩ ករណី ។ ពុំមានមន្ត្រីជាស្ត្រីណាម្នាក់ បានទទួលការបណ្តុះបណ្តាលនៅបរទេសលើសពីបីខែ ប្រៀបធៀបនឹងមន្ត្រីជាបុរសបានទទួល ១០ ករណី ហើយមន្ត្រីជាស្ត្រីបានទទួលការបណ្តុះបណ្តាលនៅបរទេសតិចជាង បីខែចំនួន៥ករណី ( ១១ ភាគរយ) ប្រៀបធៀបនឹងបុរស ទទួលបាន ៤០ ករណី ( សូមមើលក្រាហ្វិកទី ៥ និង ទី៦) ។ តួលេខនេះ បង្ហាញពីវិសមភាពរវាងមន្ត្រីជាស្ត្រីនិងបុរសក្នុងការទទួលការបណ្តុះបណ្តាល ដូច្នេះការផ្តល់ឱកាសដល់មន្ត្រីជាស្ត្រីអោយទទួលការបណ្តុះបណ្តាលមានសារៈសំខាន់បំផុត ដើម្បីបន្ថយគំលាតនេះ ។

## ក្រាហ្វិក ទី ៥: ការបណ្តុះបណ្តាលរបស់មន្ត្រីនៅក្រសួងព័ត៌មាន




*ប្រភព: ទិន្នន័យក្រសួងព័ត៌មាន, ឆ្នាំ ២០០៦*

## ក្រាហ្វិកទី ៦: ការបណ្តុះបណ្តាលបន្តរបស់មន្ត្រីជាបុរស និង ស្ត្រីនៅក្រសួងព័ត៌មាន




*ប្រភព: ទិន្នន័យក្រសួងព័ត៌មាន, ២០០៦ខ*

## ២.៥ សកម្មភាពនៃវិស័យព័ត៌មានទាក់ទងនឹងយេនឌ័រ

វិស័យព័ត៌មាននៅប្រទេសកម្ពុជាបានរីកចំរើនគួរឱ្យកត់សំគាល់ក្រោយការផ្លាស់ប្តូររបបនយោបាយពីរដ្ឋកម្ពុជា ទៅព្រះរាជាណាចក្រអាស្រ័យរដ្ឋធម្មនុញ្ញក្រោយការបោះឆ្នោតជាសកលនៅប្រទេសកម្ពុជានាឆ្នាំ ១៩៩៣។ យោងតាមការពិភាក្សាជាមួយសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រនៅក្រសួងព័ត៌មានបានបង្ហាញថាការផ្សព្វផ្សាយអំពីស្ត្រីតាមប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជាមានចំនួនតិចតួចបំផុត ដូច្នេះ ត្រូវបង្កើនការផ្សព្វផ្សាយអំពីស្ត្រីតាមប្រព័ន្ធឃោសនាអោយបានទូលំទូលាយ។

សកម្មភាពបញ្ជ្រាបយេនឌ័រនៅក្រសួងព័ត៌មាននៅមានចំនួនតិចតួច ហើយសកម្មភាពត្រូវបង្កើនជាការចាំបាច់។ ចាប់តាំងពីទសវត្សរ៍ទី ៩០ ក្រសួងព័ត៌មានបានសហការជាមួយជាមួយក្រសួងនិងស្ថាប័ននានា ជាពិសេសជាមួយក្រសួងកិច្ចការនារី ដើម្បីប្រារព្ធទិវាអន្តរជាតិនារី ៨ មិនា។ ភាគច្រើននៃសកម្មភាពនាទិវានេះគឺការជួបជុំគ្នា និងការដើរកំសាន្ត និងការពិភាក្សាពីតួនាទីរបស់ស្ត្រី។ ការផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រ សំរាប់បុគ្គលិកនៃក្រសួងព័ត៌មានមានចំនួនតិចតួច។ រហូតមកដល់ពេលនេះមានបុគ្គលិកក្រសួងព័ត៌មានចំនួន ៧ នាក់ (ស្ត្រី ៥ រូប និង បុរស ២ រូប) បានទទួលការបណ្តុះបណ្តាលជាគ្រូបង្គោលផ្នែកយេនឌ័រ។ នៅក្រោមការឧបត្ថម្ភផ្នែកថវិកាពីអង្គការ UNFPA ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងព័ត៌មាននិងក្រុមគ្រូបង្គោលនៃក្រសួងកិច្ចការនារី បានផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រចំនួនប្រាំវគ្គ ដែលមានសិក្ខាកាមចូលរួមចំនួនសរុបចំនួន ១៨៣ រូបដែលក្នុងនោះមាន ស្ត្រី ៨៥ រូប និងបុរស ៩៨ រូប។ សិក្ខាកាមទាំងនេះរួមមានថ្នាក់ដឹកនាំថ្នាក់នាយកដ្ឋាន, ការិយាល័យ និងបុគ្គលិក និងបណ្តាអ្នកសារព័ត៌មានអោយបណ្តាស្ថានីយ៍វិទ្យុទូរទស្សន៍ កាសែត និងទស្សនាវដ្តីរបស់រដ្ឋ និងឯកជន។ ការផ្តល់វគ្គបណ្តុះបណ្តាលអំពីការស្វែងយល់អំពីយេនឌ័រជូនសិក្ខាកាមទាំងនេះ មានសារសំខាន់យ៉ាងខ្លាំងក្នុងការបន្តផ្សព្វផ្សាយយេនឌ័រទៅក្នុងសង្គម។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះគេពុំទាន់ធ្វើការវាយតំលៃអំពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលទាំងនេះទេ។

## ២.៦ ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន

ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មានត្រូវបានបង្កើតនៅឆ្នាំ ២០០៥ ដោយមានសមាជិកជាមន្ត្រីព័ត៌មានចំនួន៧នាក់មកពីអគ្គនាយកដ្ឋាន និងនាយកដ្ឋានផ្សេងៗក្រោមឱវាទក្រសួងព័ត៌មាន ហើយមានឯកឧត្តមលេខាធិការរដ្ឋ លេខាធិការជាប្រធាន។ ក្រុមការងារនេះមានតួនាទី:

- សំរបសំរួល សហការ និងស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីបណ្តាស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងអន្តរជាតិ ដើម្បីលើកកំពស់ការងារយេនឌ័រក្នុងវិស័យព័ត៌មាន
- ផ្សព្វផ្សាយ និង បណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័រដល់មន្ត្រីក្រសួងព័ត៌មាននៅគ្រប់ថ្នាក់ចាប់ តាំងពីថ្នាក់កណ្តាល បណ្តាខេត្ត-ក្រុង និង ថ្នាក់មូលដ្ឋាន និងដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់
- ចូលរួមជំរុញផ្តល់ការបណ្តុះបណ្តាល និង តួនាទីសមរម្យដល់មន្ត្រីក្រសួងព័ត៌មានជាស្ត្រី
- ចូលរួមក្នុងការធ្វើផែនការរបស់ក្រសួងព័ត៌មានដើម្បីធានាថាកម្មវិធីទាំងនោះឆ្លើយតបនឹងតំរូវ ការយេនឌ័រ
- ត្រួតពិនិត្យ និង វាយតំលៃរាល់សកម្មភាពទាក់ទងនឹងយេនឌ័រនៅក្នុងវិស័យព័ត៌មាន

# ជំពូកទី ៣
# យុទ្ធសាស្ត្រ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ

## ៣.១ យុទ្ធសាស្ត្រ

ដើម្បីធានាថាទាំងបុរស និងស្ត្រីបានទទួលសមធម៌ក្នុងការទទួលផលប្រយោជន៍ពីគ្រប់សកម្មភាពព័ត៌មាន និងទទួលបានសមធម៌យេនឌ័រក្នុងវិស័យព័ត៌មានអោយកាន់តែប្រសើរឡើង ស្ត្រីនិងបុរសគួរតែមានឱកាសស្មើគ្នាក្នុងការចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាល និងការធ្វើសេចក្តីសំរេចផ្សេងៗ ក្នុងការងារក៏ដូចជាការទទួលព័ត៌មាន។ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មានជាមូលដ្ឋានគ្រឹះក្នុងការលើកកំពស់ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា ដើម្បីអោយស្ត្រីនិងកុមារមានឱកាសកាន់តែប្រសើរក្នុងការទទួលផលប្រយោជន៍ពីគ្រប់សកម្មភាពផ្សព្វផ្សាយព័ត៌មាន។ ក្រសួងព័ត៌មានមានតួនាទីដ៏សំខាន់ក្នុងការផ្សព្វផ្សាយរាល់ព័ត៌មានអំពីយេនឌ័រដល់សាធារណជនតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួនក្នុងគោលបំណងលើកកំពស់យេនឌ័រ និងផ្លាស់ប្តូរឥរិយាបទអវិជ្ជមានចំពោះស្ត្រី។ ដើម្បីសំរេចការងារនេះ ក្រសួងព័ត៌មានមានយុទ្ធសាស្ត្រដូចតទៅ:

១. បង្កើនការផ្សព្វផ្សាយអំពីយេនឌ័រដល់សាធារណៈជនទូទៅ

២. បង្កើនចំណេះដឹងអំពីយេនឌ័រដល់ប្រព័ន្ធផ្សព្វផ្សាយគ្រប់លំដាប់ថ្នាក់

៣. បញ្ចូលផែនការអំពីការផ្សព្វផ្សាយស្តីពីយេនឌ័រទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន

៤. បង្កើនចំណេះដឹង ជំនាញសមត្ថភាព និងទំនុកចិត្តដល់បុគ្គលិកនៃក្រសួងព័ត៌មានជាពិសេសមន្ត្រីជាស្ត្រីតាមរយៈការបង្កើនការចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស

៥. ផ្តល់ឱកាស និងលើកទឹកចិត្តដល់មន្ត្រីក្រសួងព័ត៌មានជាស្ត្រីក្នុងការទទួលបានតំណែងធ្វើសេចក្តីសំរេច ដើម្បីកាត់បន្ថយគំលាតរវាងមន្ត្រីជាបុរសនិងស្ត្រី

៦. តាមដាន និងវាយតំលៃលើការងាររបស់ក្រសួងព័ត៌មានដើម្បីធានាថារាល់កម្មវិធី និងសកម្មភាពមានការឆ្លើយតបនឹងការងារយេនឌ័រ

## ៣.២ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររយៈពេល ៥ ឆ្នាំ ២០០៦-២០១០

ដើម្បីអនុវត្តផែនការបញ្ជ្រាបយេនឌ័រដោយជោគជ័យ វាជាការចាំបាច់ណាស់ក្នុងការប្រែក្លាយយុទ្ធសាស្ត្រទាំងនេះទៅជាសកម្មភាពដែលអាចអនុវត្តបាន រួមជាមួយសូចនាករដើម្បីបញ្ជាក់ថាតើសកម្មភាពទាំងនោះត្រូវបានអនុវត្តក្នុងកំរិតណា និងចំនុចដៅនាឆ្នាំ ២០១០ ដែលបញ្ជាក់ពីគោលដៅដែលសកម្មភាពទាំងឡាយនឹងអាចសំរេចបានក្នុងរយៈពេល ៥ ឆ្នាំ។

## យុទ្ធសាស្ត្រទី ១: បង្កើនការយល់ដឹងអំពីយេនឌ័រដល់ប្រជាពលរដ្ឋគ្រប់លំដាប់នៅក្នុងសង្គម

ក្រសួងព័ត៌មានមានតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនសារយេនឌ័រដល់ប្រជាជនគ្រប់ស្រទាប់នៅទូទាំងប្រទេសកម្ពុជាតាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតដោយសារប្រព័ន្ធទាំងនេះមានប្រសិទ្ធភាពខ្ពស់ក្នុងការចែកចាយព័ត៌មានអំពីតួនាទី និងតំរូវការរបស់ស្ត្រីផ្នែកការអប់រំសុខាភិបាល ច្បាប់ការងារកសិកម្មសេដ្ឋកិច្ច សិទ្ធិរបស់ស្ត្រី អំពើហិង្សាលើស្ត្រី ការរំលោភបំពាន និងការជួញដូរមនុស្ស ។ ការផ្សព្វផ្សាយអំពីយេនឌ័រនេះមានគោលបំណងផ្តល់ចំណេះដឹងអំពីយេនឌ័រ ដើម្បីផ្លាស់ប្តូរអកប្បកិរិយា និងឥរិយាបទអវិជ្ជមានចំពោះស្ត្រី និងបុរស ។ ការផ្សព្វផ្សាយសារអំពីយេនឌ័រតាមប្រព័ន្ធឃោសនាជាពិសេស តាមវិទ្យុនិងទូរទស្សន៍មានសារៈសំខាន់បំផុត ដោយសារសកម្មភាពបែបនេះនៅមានតិចតួចនៅឡើយនៅក្នុងសកម្មភាពផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន ។ ក្រសួងព័ត៌មានមិនត្រឹមតែជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប៉ុណ្ណោះទេ ប៉ុន្តែជាមជ្ឈមណ្ឌលសំរាប់ផលិតយុទ្ធសាស្ត្រ និងស្វែងរកការគាំទ្រយេនឌ័រ ។ ការផលិតយុទ្ធសាស្ត្រនិងស្វែងរកការគាំទ្រយេនឌ័រគប្បីផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ ក្រោមការសហការ ជាមួយយុទ្ធនាការស្វែងរកការគាំទ្រ និងប្រាស្រ័យទាក់ទងអំពីយេនឌ័រ ***គំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រ*** ដែលនឹងបន្តពីឆ្នាំ ២០០៦ រហូត ដល់ ២០០៩។

- ចូលរួមក្នុងការស្រាវជ្រាវជាមូលដ្ឋានដើម្បីរៀបចំយុទ្ធនាការលើកកំពស់យេនឌ័រតាមប្រព័ន្ធ ផ្សព្វផ្សាយ
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រសំរាប់យុទ្ធនាការផ្សព្វផ្សាយលើកកំពស់យេនឌ័រ
- រៀបចំកម្មវិធីពិភាក្សាតាមទូរទស្សន៍ និងវិទ្យុអំពីយេនឌ័រជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលមន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- រៀបចំកិច្ចសំភាសន៍តាមវិទ្យុ និងទូរទស្សន៍អំពីយេនឌ័រជាមួយប្រជាពលរដ្ឋនៅគ្រប់លំដាប់ថ្នាក់ និងគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា
- បញ្ជ្រាបសារអំពីយេនឌ័រទៅក្នុងកម្មវិធីផ្សព្វផ្សាយនានាប្រចាំថ្ងៃ
- ផ្តល់កិច្ចសំភាសន៍ទៅអោយស្ថានីយ៍តាមបណ្តាខេត្តដើម្បីផ្សព្វផ្សាយបន្ត
- រៀបចំសកម្មភាពលើកកំពស់យេនឌ័រ ស្របតាមប្រធានបទនានានៃទិវាអន្តរជាតិនារី ៨ មិនា

### សូចនាករ[៥]

- ការស្រាវជ្រាវជាមូលដ្ឋានបានបញ្ចប់ដោយមានការចូលរួមពីក្រុមការងារបច្ចេកទេសយេនឌ័រនៃ ក្រសួងព័ត៌មាន
- ផែនការយុទ្ធសាស្ត្រត្រូវបានរៀបចំដោយមានការចូលរួមពីក្រុមការងារបច្ចេកទេស យេនឌ័រនៃក្រសួងព័ត៌មាន
- ចំនួនសារ និង របាយការណ៍នៃបទសំភាសន៍ដែលបានចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍
- ចំនួនសារ និង ទស្សនៈប្រជាពលរដ្ឋដែលបានស្តាប់ និង ទស្សនាបទសំភាសន៍
- ចំនួនសារ និង ព័ត៌មានអំពីយេនឌ័រដែលត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីផ្សព្វផ្សាយប្រចាំថ្ងៃ
- ចំនួនសារ និង របាយការណ៍នៃការចែកចាយការសំភាសន៍ទៅអោយស្ថានីយ៍តាមខេត្ត-ក្រុង
- បណ្តាសកម្មភាពលើកកំពស់យេនឌ័រត្រូវបានអនុវត្តនាទិវាអន្តរជាតិនារី ៨ មិនា

### ចំនុចដៅឆ្នាំ ២០១០

- ៨៥ ភាគរយនៃប្រជាពលរដ្ឋនៅគ្រប់ខេត្ត-ក្រុងបានលឺ ឬ ទស្សនាការផ្សព្វផ្សាយអំពីយេនឌ័រតាម វិទ្យុ ទូរទស្សន៍ និង តាមរូបភាពផ្សេងៗទៀតយ៉ាងហោចណាស់មួយដងក្នុងមួយខែ
- ការផ្លាស់ប្តូរឥរិយាបទអវិជ្ជមានចំពោះស្ត្រី និងបុរសដូចដែលបានកំណត់នៅក្នុងផែនការសកម្មភាពយុទ្ធនាការលើកកំពស់យេនឌ័រ
- ៥០ ភាគរយនៃកម្មវិធីផ្សព្វផ្សាយព័ត៌មានប្រចាំថ្ងៃបានបញ្ចូលសារអំពីយេនឌ័រ
- គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍ខេត្ត-ក្រុងបានផ្សាយបន្តសារអំពីយេនឌ័រ
- រាល់ទិវាអន្តរជាតិនារី ៨ មិនាបានបញ្ចូលប្រធានបទយេនឌ័រ

## យុទ្ធសាស្ត្រទី ២: បង្កើនការយល់ដឹងអំពីយេនឌ័រនៅក្នុងវិស័យព័ត៌មានតាមគ្រប់លំដាប់ថ្នាក់

ការផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់មន្ត្រីព័ត៌មានទាំងពីរភេទនៅគ្រប់លំដាប់ថ្នាក់ជាការចាំបាច់ ដោយសារការបណ្តុះបណ្តាលអំពីយេនឌ័រសំរាប់មន្ត្រីព័ត៌មានដែលបានធ្វើកន្លងមកមានចំនួនតិចតួច ហើយចំណេះដឹងអំពីយេនឌ័ររបស់មន្ត្រីព័ត៌មានអាចមានកំរិតដោយសារការបណ្តុះបណ្តាលអំពីយេនឌ័រមានចំនួនតិចតួច និងពុំមានការបញ្ចូលប្រធានបទយេនឌ័រនៅក្នុងការបណ្តុះបណ្តាលព័ត៌មាននានា។ ដូច្នេះវាជាការចាំបាច់ក្នុងការផ្តល់ការបង្កើនការយល់ដឹងអំពីយេនឌ័រដល់មន្ត្រីព័ត៌មានតាមរយៈការបណ្តុះបណ្តាល និងការចែកចាយព័ត៌មាន។ ក្រុមការងារបញ្ជ្រាបយេនឌ័រនឹងសហការជាមួយ ***គំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រនៃក្រសួងកិច្ចការនារី*** និងស្ថាប័ននានា ដើម្បីធ្វើការបណ្តុះបណ្តាល។

### សកម្មភាព

- បណ្តុះបណ្តាលអំពីបច្ចេកទេសក្នុងការសំរបសំរួលវគ្គដោយមានការចូលរួម (participatory training) អំពីការបាន់ប្រមាណយេនឌ័រ និងយុទ្ធសាស្ត្រស្វែករកការគាំទ្រយេនឌ័រដល់ក្រុមការងារបច្ចេកទេសយេនឌ័រនៅក្រសួងព័ត៌មាន
- បង្កើនការបណ្តុះបណ្តាលគ្រូបង្គោលយេនឌ័រនៅក្រសួងព័ត៌មាន
- បង្កើត និង បណ្តុះបណ្តាលក្រុមការងារបច្ចេកទេសយេនឌ័រថ្នាក់ខេត្ត-ក្រុងនៃមន្ទីរព័ត៌មានដែលមានសមាជិក ៥ នាក់ និងមានតួនាទី និងភារកិច្ចក្រុមការងារបច្ចេកទេសយេនឌ័រនៅថ្នាក់ជាតិ
- បណ្តុះបណ្តាលអំពីយេនឌ័រដល់បណ្តាញអ្នកសារព័ត៌មាន ពិធីករ សិល្បៈករ និងផលិតករក្នុងក្របខ័ណ្ឌក្រសួងព័ត៌មានអំពីអំពីការបាន់ប្រមាណយេនឌ័រ និងយុទ្ធសាស្ត្រស្វែករកការគាំទ្រយេនឌ័រ
- បញ្ចូលប្រធានបទយេនឌ័រទៅក្នុងវគ្គបណ្តុះបណ្តាលនានារបស់ក្រសួងព័ត៌មាន

### សូចនាករ

- ចំនួនក្រុមការងារបច្ចេកទេសយេនឌ័រនៃមន្ទីរព័ត៌មានថ្នាក់ខេត្ត-ក្រុងត្រូវបានបង្កើត និងភ្ជាប់ជាមួយ តួនាទី និង ភារកិច្ច
- ចំនួនវគ្គបណ្តុះបណ្តាលដែលរាល់សមាជិកក្រុមការងារបច្ចេកទេសយេនឌ័ររបស់ក្រសួងព័ត៌មានបានទទួល
- ចំនួនគ្រូបង្គោលយេនឌ័រត្រូវទទួលបានបណ្តុះបណ្តាល
- ចំនួនវគ្គនិងចំនួនសិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីយេនឌ័រ
- ចំនួនវគ្គបណ្តុះបណ្តាលផ្នែកព័ត៌មានដែលបានបញ្ចូលប្រធានបទយេនឌ័រ

### ចំនុចដៅនៅឆ្នាំ ២០១០

- ៨០ ភាគរយនៃថ្នាក់ដឹកនាំនៃក្រសួងព័ត៌មាននៅកំរិតអគ្គនាយកដ្ឋាន នាយកដ្ឋាន និង ការិយាល័យនៅថ្នាក់ជាតិ និង ខេត្ត-ក្រុងបានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ
- ២៥ ភាគរយបុគ្គលិកនៃក្រសួងព័ត៌មាននៅថ្នាក់ជាតិ និង ខេត្ត-ក្រុងបានទទួលការបណ្តុះបណ្តាល អំពីយេនឌ័រ
- ៥០ ភាគរយនៃអ្នកសារព័ត៌មានរដ្ឋ និង ឯកជនបានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ
- ២០ ភាគរយនៃអ្នកសារព័ត៌មានឯកជនបានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ
- ៥០ ភាគរយនៃសិល្បករ ផលិតករក្នុងក្របខ័ណ្ឌក្រសួងព័ត៌មានបានទទួលការបណ្តុះបណ្តាលអំពី យេនឌ័រ
- ២០ ភាគរយនៃវគ្គបណ្តុះបណ្តាលអំពីវិស័យព័ត៌មានបានបញ្ចូលប្រធានបទយេនឌ័រ

## យុទ្ធសាស្ត្រទី ៣៖ បញ្ចូលទិន្នន័យ សូចនាករ និងអ្នកទទួលផលប្រយោជន៍ដោយបែងចែកពីភេទទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន

ជារៀងរាល់ឆ្នាំ នាយកដ្ឋានផែនការនៃក្រសួងព័ត៌មានទទួលបន្ទុកប្រមូលនិងដាក់បញ្ចូលគ្នានូវផែនការសកម្មភាពរបស់នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងដើម្បីរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន។ ដូច្នេះវាជាការចាំបាច់ណាស់ដែលក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មានត្រូវសហការជាមួយនាយកដ្ឋានផែនការដើម្បីចូលរួមប្រជុំពិគ្រោះដើម្បីពិភាក្សា និងផ្តល់យោបល់លើផែនការ សកម្មភាពរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងព័ត៌មានដើម្បីអោយផែនការប្រតិបត្តិរបស់ក្រសួងព័ត៌មានឆ្លុះបញ្ចាំងពីយេនឌ័រ។ ជាបន្ថែម ក្រុមការងារយេនឌ័រនៃក្រសួងព័ត៌មានគប្បីសហការជាមួយនាយកដ្ឋានស្ថិតិជាតិនៃក្រសួងផែនការ ដើម្បីចូលរួមផ្តល់យោបល់លើការអង្កេតនានាលើវិស័យព័ត៌មាន ដើម្បីធានាថាការអង្កេតទាំងនេះបានឆ្លុះបញ្ចាំងពីយេនឌ័រ។

### សកម្មភាព

- បញ្ជូនសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រទៅក្នុងក្រុមរៀបចំផែនការប្រតិបត្តិរបស់ក្រសួងព័ត៌មាន
- បណ្តុះបណ្តាលក្រុមការងារពីការរៀបចំផែនការប្រតិបត្តិដោយឆ្លើយតបនឹងយេនឌ័រ

- ដាក់បញ្ចូលសូចនាករដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងបុរស និងស្ត្រីផ្នែកតំរូវការផ្នែកព័ត៌មានទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន
- ដាក់បញ្ចូលសូចនាករដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងបុរស និងស្ត្រីផ្នែកតំរូវការផ្នែកព័ត៌មានទៅក្នុងការធ្វើជំរឿនប្រជាជនឆ្នាំ ២០០៨

### សូចនាករ

- ក្រុមការងារទទួលការបណ្តុះបណ្តាល
- របាយការណ៍ពិពណ៌នាពីភាពខុសគ្នារវាងបុរស និងស្ត្រីក្នុងការទទួលសេវាព័ត៌មានអំពីយេនឌ័រនៅតាមទីក្រុង និងទីជនបទ
- ទិន្នន័យដែលមានការបែងចែកតាមភេទអំពីការទទួលសេវាព័ត៌មានត្រូវបានវិភាគ និងប្រើប្រាស់
- សូចនាករឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងបុរសនិងស្ត្រី អំពីតំរូវការ បញ្ហា ទស្សនៈអំពីគុណភាពនៃសេវាព័ត៌មាន ការផ្តល់សេវាព័ត៌មាន ការទទួលសេវាព័ត៌មាន ត្រូវបានបញ្ចូលក្នុងរាល់ការស្រាវជ្រាវ និងការធ្វើជំរឿនប្រជាជនឆ្នាំ ២០០៨ របស់ក្រសួងផែនការ

### ចំនុចដៅនៅឆ្នាំ ២០១០

- ក្រុមការងារមានជំនាញ និង សមត្ថភាពក្នុងការរៀបចំផែនការឆ្លើយតបនឹងយេនឌ័រ
- ១០០ ភាគរយនៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មានឆ្លើយតបទៅនឹងតំរូវការយេនឌ័រ
- ១០០ ភាគរយនៃរបាយការណ៍ និងទិន្នន័យនៃសេវាព័ត៌មានបានពិពណ៌នាអំពីភាពខុសគ្នារវាងបុរស និងស្ត្រីក្នុងការទទួលសេវាព័ត៌មាន
- ១០០ ភាគរយនៃការអង្កេតស្រាវជ្រាវរបស់ក្រសួងព័ត៌មាន និងស្ថាប័នផ្សេងៗបានពិនិត្យលើតំរូវការ និងទស្សនៈរវាងស្ត្រី និងបុរសអំពីគុណភាព និងការទទួលសេវាព័ត៌មាន

## យុទ្ធសាស្ត្រទី ៤: បង្កើនចំណេះដឹង ជំនាញ សមត្ថភាព និងទំនុកចិត្តរបស់មន្ត្រីជាស្ត្រីតាមរយៈការបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស

ក្រសួងព័ត៌មានមានភារកិច្ចបង្កើនចំណេះដឹង សមត្ថភាពនិងជំនាញរបស់មន្ត្រីព័ត៌មានទាំង ២ ភេទ។ ដោយសារចំនួនមន្ត្រីជាស្ត្រីដែលទទួលការបណ្តុះបណ្តាលបន្តទាំងក្នុង និងក្រៅប្រទេសក្នុងរយៈពេលខ្លី និងវែង មានចំនួនតិចជាងចំនួនមន្ត្រីព័ត៌មានជាបុរសនោះ ការបង្កើនការផ្តល់ការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងផ្នែកការងារបច្ចេកទេសទាក់ទងនឹងការងារ និងផ្នែកភាសាអង់គ្លេសជូនមន្ត្រីព័ត៌មានជាស្ត្រីមានសារៈសំខាន់ណាស់ក្នុងការ បង្កើនសមត្ថភាព និងទំនុកចិត្តរបស់គាត់ក្នុងការបំពេញការងារនឹងជាជំហាន ដើម្បីទទួលបានការបណ្តុះបណ្តាលនៅបរទេស។ ជាបន្ថែម ក្រុមការងារបច្ចេកទេសយេនឌ័រត្រូវធ្វើការជាមួយអគ្គនាយកដ្ឋាននានារបស់ក្រសួងព័ត៌មាន ដើម្បីបង្កើតល័ក្ខខ័ណ្ឌអនុគ្រោះសំរាប់មន្ត្រីព័ត៌មានជាស្ត្រីអោយទទួលបានការបណ្តុះបណ្តាល។ ជាបន្ថែម ការផ្តល់ចំណេះដឹង និងជំនាញ

ក្នុងការវិភាគទិន្នន័យ ការសំរបសំរួល និងការគាំទ្របច្ចេកទេសដល់ក្រុមការងារបច្ចេកទេសយេនឌ័រជាគន្លឹះសំរាប់ការលើកកំពស់យេនឌ័រក្នុងវិស័យព័ត៌មាន។

### សកម្មភាព:

- បង្កើតនិតិវិធីអនុគ្រោះដើម្បីបង្កើនចំនួនមន្ត្រីព័ត៌មានជាស្ត្រីអោយទទួលបានការបណ្តុះបណ្តាលបន្ត
- សំរបសំរួលជាមួយបណ្តាស្ថាប័នរដ្ឋាភិបាល ស្ថាប័នម្ចាស់ជំនួយ និងអង្គការនានា ដើម្បីផ្តល់នូវការគាំទ្រលើល័ក្ខខ័ណ្ឌអនុគ្រោះចំពោះស្ត្រី
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសសំភាសន៍ បច្ចេកទេសប្រមូល និងវិភាគទិន្នន័យទាក់ទងនឹងយេនឌ័រដល់ក្រុមការងារបច្ចេកទេសយេនឌ័រ
- ផ្តល់ការបណ្តុះបណ្តាលជំនាញរយៈពេលវែង និងខ្លីក្នុងនិងក្រៅប្រទេស ដល់មន្ត្រីក្រសួងព័ត៌មានជាស្ត្រី ដើម្បីបង្កើនចំណេះដឹង ជំនាញ សមត្ថភាព និងទំនុកចិត្តក្នុងការងារ
- ជ្រើសរើសមន្ត្រីព័ត៌មានថ្មី បេក្ខនារីត្រូវបានលើកកំពស់

### សូចនាករ

- ឯកសារអំពីល័ក្ខខ័ណ្ឌអនុគ្រោះចំពោះមន្ត្រីក្រសួងព័ត៌មានជាស្ត្រីដើម្បីទទួលបានការបណ្តុះបណ្តាលផ្សេងៗត្រូវបានបង្កើត
- ចំនួនស្ថាប័នរដ្ឋ ម្ចាស់ជំនួយ និងអង្គការនានាដែលបានផ្តល់ការគាំទ្រលើល័ក្ខខ័ណ្ឌអនុគ្រោះ ចំពោះបុគ្គលិកជាស្ត្រីក្នុងការទទួលការបណ្តុះបណ្តាល
- របាយការណ៍ និងចំនួនមន្ត្រីក្រសួងព័ត៌មានជាស្ត្រីដែលបានទទួលការបណ្តុះបណ្តាលរយៈពេលវែង និងខ្លីទាំងក្នុងនិងក្រៅប្រទេស
- សមាជិកក្រុមការងារបច្ចេកទេសយេនឌ័រត្រូវបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសសំភាសន៍ ប្រមូល និងវិភាគ ទិន្នន័យទាក់ទងនឹងយេនឌ័រ
- របាយការណ៍នៃការជ្រើសរើស និងចំនួនមន្ត្រីព័ត៌មានជាស្ត្រី និងបុរសដែលចូលបំរើការងារថ្មី

### ចំនុចដៅឆ្នាំ ២០១០

- ៣០ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលក្រៅស្រុក
- ១០ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីទទួលការបណ្តុះបណ្តាលក្នុងស្រុកយ៉ាងតិចបំផុត ១ ដង ក្នុងរយៈពេល ១២ ខែ
- ៥ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីទទួលការបណ្តុះបណ្តាលនៅបរទេសយ៉ាងតិចបំផុត ១ ដង ក្នុងរយៈពេល ១២ ខែ ទៅតាមតំរូវការម្ចាស់ជំនួយ
- ១០០ ភាគរយនៃក្រុមការងារបច្ចេកទេសយេនឌ័របានទទួលការបណ្តុះបណ្តាលក្នុងការប្រមូល និងវិភាគទិន្នន័យដែលឆ្លុះបញ្ចាំងពីយេនឌ័រ
- រាល់ការជ្រើសរើសមន្ត្រីព័ត៌មានថ្មីបេក្ខនារីត្រូវបានលើកកំពស់

## យុទ្ធសាស្ត្រទី ៥៖ ផ្តល់ឱកាសការលើកទឹកចិត្ត និងលក្ខខណ្ឌអំណោយផលដល់មន្ត្រីក្រសួងព័ត៌មានជាស្ត្រី ក្នុងការទទួលបានតំណែងក្នុងថ្នាក់ដឹកនាំក្រសួងព័ត៌មាន

មន្ត្រីព័ត៌មានជាស្ត្រីមានតំណែងក្នុងការធ្វើការសំរេចមានចំនួនតិចជាងបុរសជាច្រើនគិតចាប់ពីថ្នាក់ការិយាល័យថ្នាក់ស្រុករហូតដល់ថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្រសួងព័ត៌មាន។ ការពិចារណាពីការផ្តល់តំណែងមន្ត្រីព័ត៌មានជាស្ត្រីជាចាំបាច់ដើម្បីលើកកំពស់សមភាព និងសមធម៌យេនឌ័រនៅក្នុងក្រសួងព័ត៌មាន។ ដើម្បីសំរេចគោលបំណងនេះ ការផ្តល់ការបណ្តុះបណ្តាលផ្នែកការគ្រប់គ្រង ជំនាញបច្ចេកទេស និងភាសាសំរាប់មន្ត្រីព័ត៌មានជាស្ត្រីមានសារសំខាន់បំផុត។ ក្រុមការងារបច្ចេកទេសយេនឌ័ររបស់ក្រសួងព័ត៌មាន គប្បីចូលរួមក្នុងគណៈកម្មការវាយតំលៃ តំឡើងឋានន្តរសក្តិ និងថ្នាក់មន្ត្រីទាំងពីរភេទ។

### សកម្មភាព

- សំរបសំរួល និង បង្កល័ក្ខខ័ណ្ឌអនុគ្រោះចំពោះមន្ត្រីក្រសួងព័ត៌មានជាស្ត្រីដើម្បីទទួលបានតំណែងក្នុងថ្នាក់ដឹកនាំក្រសួងព័ត៌មាន
- សម្របសំរួល និង ជំរុញឱ្យមានការតំឡើងឋានៈតួនាទីដល់មន្ត្រីជាស្ត្រីអោយទទួលតំណែងជាប្រធាន ឬអនុប្រធានមន្ទីរព័ត៌មានថ្នាក់ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុង នាយកដ្ឋាន និងអគ្គនាយកដ្ឋាន

### សូចនាករ

- និតិវិធីនៃការតែងតាំង និង សេចក្តីពិពណ៌នាការងារត្រូវបានបង្កើត
- សំរបសំរួលអោយមានការតែងតាំង និង តំឡើងតំណែងដោយផ្អែកលើសមត្ថភាព និង គុណភាពការងារ
- ចំនួន និង ភាគរយមន្ត្រីក្រសួងព័ត៌មានជាស្ត្រីដែលបានទទួលការតែងតាំងតួនាទីជាប្រធាន ឬអនុ ប្រធានស្ថាប័នព័ត៌មានចាប់តាំងពីថ្នាក់ស្រុក-ខ័ណ្ឌ, ខេត្ត-ក្រុង នាយកដ្ឋាន អគ្គនាយកដ្ឋាន និងសមាជិករាជរដ្ឋាភិបាលនៃក្រសួងព័ត៌មាន

### ចំនុចដៅក្នុងឆ្នាំ ២០១០

- ២៥ ភាគរយនៃមន្ត្រីជាស្ត្រីទទួលបានតំណែងជាអគ្គនាយក-អគ្គនាយករង, ប្រធាន និង អនុប្រធាន នាយកដ្ឋាន
- ២៥ ភាគរយនៃមន្ត្រីជាស្ត្រីទទួលបានតំណែងប្រធាន និងអនុប្រធានមន្ទីរព័ត៌មានខេត្ត-ក្រុង និងប្រធានអនុប្រធានការិយាល័យព័ត៌មានស្រុក-ខ័ណ្ឌ

## យុទ្ធសាស្ត្រទី៦: ធ្វើការតាមដាន និងវាយតំលៃរាល់កម្មវិធី និងសកម្មភាពរបស់ក្រសួងព័ត៌មាន ដើម្បីធានាថារាល់កម្មវិធី និងសកម្មភាពទាំងនោះមានការឆ្លើយតបនឹងតំរូវការយេនឌ័រ

ការវាយតំលៃកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រគប្បីធ្វើឡើងជាបន្តបន្ទាប់ ដោយប្រើទាំងបច្ចេកទេសគុណភាព និង បរិមាណ (qualitative and quantitative methods) ដើម្បីដឹងថាតើកម្មវិធីបានសំរេចចំនុចដៅ និងសូចនាករដែលឆ្លុះបញ្ចាំងពីយេនឌ័រក្នុងកំរិតណា។ ការវាយតំលៃនេះក៏ផ្តល់ឱកាសអោយស្ថាប័នព័ត៌មាន និងដៃគូអភិវឌ្ឍន៍ដែលកំពុងអនុវត្តកម្មវិធីរបស់ខ្លួនបានអនុវត្តកម្មវិធីដែលឆ្លុះបញ្ចាំងពីយេនឌ័ររបស់ខ្លួនដោយជោគជ័យ។ វាជាការចាំបាច់ណាស់ថាដើម្បីធ្វើការតាមដាន និងវាយតំលៃដោយជោគជ័យរាល់កម្មវិធីទាំងអស់ត្រូវមានសូចនាករដែលឆ្លុះបញ្ចាំងពីយេនឌ័រច្បាស់លាស់ និងអាចវាស់វែងបាន។ ដើម្បីសំរេចបេសកកម្មនេះក្រុមការងារយេនឌ័រត្រូវមានចំណេះដឹងក្នុងការវិភាគទិន្នន័យ ការធ្វើផែនការព័ត៌មាន ការសំរបសំរួល និងការតស៊ូមតិ។ ក្រុមការងារយេនឌ័រនៃក្រសួងព័ត៌មានត្រូវសហការជាមួយ និងផ្តល់យោបល់ជូនអគ្គនាយកដ្ឋានជំនាញក្រោមឱវាទក្រសួង ជាពិសេសជាមួយនាយកដ្ឋានផែនការ អនុវត្តសកម្មភាព និងសំរេចគោលដៅដែលបានកំណត់ខាងលើ ដោយជោគជ័យ។

### សកម្មភាព

- ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារបច្ចេកទេសយេនឌ័រក្នុងការតាមដាន និងវាយតំលៃកម្មវិធីព័ត៌មានដែលឆ្លើយតបនឹងយេនឌ័រ
- រៀបចំ និងពិនិត្យរបាយការណ៍នៃសេវាព័ត៌មានឆ្លើយតបនឹងយេនឌ័រ
- ពិនិត្យការអនុវត្តដោយជោគជ័យនូវ សូចនាករដែលកំណត់ខាងលើ

### សូចនាករ

- គ្រប់សមាជិកក្រុមការងារបច្ចេកទេសយេនឌ័រដែលបានចូលរួមវគ្គបណ្តុះបណ្តាលអំពីការតាមដាន និងវាយតំលៃកម្មវិធីព័ត៌មានដើម្បីឆ្លើយតបនឹងយេនឌ័រ
- ចំនួនរបាយការណ៍ផ្នែកសេវាព័ត៌មានដែលពិពណ៌នាអំពីសូចនាករយេនឌ័រ
- សូចនាករដែលបានកំណត់ខាងលើបានសំរេចដោយជោគជ័យ

### ចំនុចដៅឆ្នាំ ២០០៦-២០១០

- គ្រប់សមាជិកក្រុមការងារបច្ចេកទេសយេនឌ័រនៅក្រសួងព័ត៌មានមានជំនាញគ្រប់គ្រាន់ក្នុងការតាមដាន និងវាយតំលៃកម្មវិធី ឬ គំរោងព័ត៌មានដែលឆ្លើយតបនឹងយេនឌ័រ
- រាល់របាយការណ៍ផ្នែកព័ត៌មានបានបញ្ជាក់អំពីសូចនាករយេនឌ័រ
- រាល់ចំនុចដៅដែលបានកំណត់ខាងលើត្រូវបានសំរេចដោយជោគជ័យ

# ជំពូកទី ៤

# ការសន្និដ្ឋាន

យុទ្ធសាស្ត្រចតុកោណក្នុងអាណត្តិទី ៣ របស់រដ្ឋាភិបាលដែលបានបញ្ជាក់យ៉ាងច្បាស់ពីតួនាទីដ៏សំខាន់ របស់ស្ត្រីក្នុងគ្រួសារ និងសង្គម ដោយចែងថាស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សង្គមកម្ពុជា។ ផ្អែកលើអំណះអំណាងនេះ ក្រសួងព័ត៌មានបានបង្កើតក្រុមការងារបច្ចេកទេសយេនឌ័រ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មានក្នុងគោលបំណងផ្សព្វផ្សាយសារលើកកំពស់យេនឌ័រ សំដៅផ្លាស់ប្តូរទស្សនៈនិងឥរិយាបទអវិជ្ជមានទៅលើស្ត្រីនិងបុរស ។ ការអនុវត្តន៍ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យព័ត៌មានពឹងផ្អែកយ៉ាងខ្លាំងលើការប្តេជ្ញាចិត្ត និងការគាំទ្រដោយសុទ្ធចិត្តរបស់រាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋ។ ក្រសួងព័ត៌មាននិងបណ្តាដៃគូអភិវឌ្ឍន៍នឹងធ្វើការតាមដាន និងវាយតំលៃសមរម្យទៅលើសកម្មភាពព័ត៌មានទាំងឡាយ ដើម្បីធានាថាសកម្មភាពទាំងនេះឆ្លើយតបនឹងយេនឌ័រដើម្បីធានាថាស្ត្រី និងបុរសបានទទួលព័ត៌មាន និង ផលប្រយោជន៍ផ្សេងៗទៀតស្មើគ្នា។

ក្រសួងព័ត៌មាននឹងតាមដានសកម្មភាពនៃកម្មវិធីផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនដោយប្រសិទ្ធភាព ទាន់ពេលវេលា និងមានថវិកាគ្រប់គ្រាន់ដើម្បីធានាថាក្រសួងនឹងសំរេចដោយជោគជ័យនូវគោលបំណងរបស់កម្មវិធីផ្សព្វផ្សាយព័ត៌មាន ដែលឆ្លុះបញ្ចាំងពីយេនឌ័រ។ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មានពុំមែនជាការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មានដោយឡែកនោះទេ ប៉ុន្តែជាការងារអន្តរវិស័យនិងអង្គភាពនានាចំណុះក្រសួងព័ត៌មាន។ ការងារនេះនឹងបានទទួលជោគជ័យអាស្រ័យដោយមានការចូលរួមអនុវត្ត ការផ្តល់វិភាគទាន និងការស្វែងយល់ពីគ្រប់ភាគីទាំងអស់ ដើម្បីគាំទ្រក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន ដែលមានតួនាទីជាស្នូលក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មាន។ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មាននេះជាឯកសារនាំផ្លូវ និងតំរង់ទិសដៅសំរាប់ការអនុវត្តន៍ដោយជោគជ័យនូវទិសដៅដែលបានកំណត់ក្នុងរយៈពេល ៥ ឆ្នាំ។ ដើម្បីសំរេចគោលបំណងនេះ យើងត្រូវការរៀបចំផែនការសកម្មភាពដែលបញ្ជាក់លំអិតពីសកម្មភាពសំរាប់អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះ និងមានការគាំទ្រពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ រួមទាំងមានថវិកាគ្រប់គ្រាន់សំរាប់ការអនុវត្តន៍។

# ឧបសម្ព័ន្ធ:

ក. តារាងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យព័ត៌មាន, ២០០៦-២០១០

ខ. ឯកសារយោង

គ. សមាជិកភាពក្រុមបច្ចេកទេសយេនឌ័រនៃក្រសួងព័ត៌មាន

## ឥ. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យព័ត៌មានរយៈពេល ៥ ឆ្នាំ ២០០៦-២០១០

| *យុទ្ធសាស្ត្រទី ១: បង្កើនការយល់ដឹងអំពីយេនឌ័ររបស់ប្រជាពលរដ្ឋគ្រប់លំដាប់នៅក្នុងសង្គម* | | | | |
|---|---|---|---|---|
| **សកម្មភាព** | **ថវិកាគិតជាដុល្លារ** | **អ្នកអនុវត្ត** | **សូចនាករ** | **ចំណុចដៅឆ្នាំ ២០១០** |
| ចូលរួមក្នុងការស្រាវជ្រាវមូលដ្ឋានដើម្បីរៀបចំយុទ្ធនាការលើកកំពស់យេនឌ័រតាមប្រព័ន្ធផ្សព្វផ្សាយ | | ក្រុមការងារបច្ចេកទេសយេនឌ័រ និង ដៃគូអភិវឌ្ឍន៍ | ការស្រាវជ្រាវមូលដ្ឋានបានបញ្ចប់ដោយមានការចូលរួមពីក្រុមការងារយេនឌ័រនៃក្រសួងព័ត៌មាន | ១០០ ភាគរយនៃប្រជាពលរដ្ឋនៅគ្រប់ខេត្ត-ក្រុងបានលឺការផ្សព្វផ្សាយអំពីយេនឌ័រតាមវិទ្យុ ឬ ទូរទស្សន៍ |
| ចូលរួមរៀបចំយុទ្ធសាស្ត្រ និង ផែនការយុទ្ធសាស្ត្រ សំរាប់យុទ្ធនាការលើកកំពស់យេនឌ័រ | | | យុទ្ធសាស្ត្រ និង ផែនការយុទ្ធសាស្ត្រត្រូវបានរៀបចំដោយ មានការចូលរួមពីក្រុមការងារយេនឌ័រនៃ ក្រសួងព័ត៌មាន | ការផ្លាស់ប្តូរឥរិយាបទអវិជ្ជមានចំពោះស្ត្រី និង បុរសដូចដែលបានកំណត់នៅក្នុងផែនការសកម្មភាពយុទ្ធនាការលើក កំពស់យេនឌ័រ |
| រៀបចំសកម្មភាព សារ និង ការសំភាសន៍តាមទូរទស្សន៍និងវិទ្យុជាតិអំពីយេនឌ័រជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ | ៣៣៧ ៥០០ | ក្រុមការងារបច្ចេកទេសយេនឌ័រ និង អគ្គនាយកដ្ឋានទូរទស្សន៍ និងវិទ្យុជាតិ | ចំនួន និង របាយការណ៍នៃការសំភាសន៍ដែលបានចាក់ផ្សាយទូរទស្សន៍ និង វិទ្យុជាតិ និង ចំនួនប្រជាជន និង ទស្សនៈប្រជាពលរដ្ឋ ដែលបានស្តាប់លឺការសំភាសន៍ | គ្រប់ស្ថានីយវិទ្យុទូរទស្សន៍ខេត្ត-ក្រុងបានផ្សាយបន្តសារអំពីយេនឌ័រ |
| ចែកចាយការសំភាសដើម្បីផ្សព្វផ្សាយតាមស្ថានីយ៍ទូរទស្សន៍ ខេត្ត-ក្រុង | ៨០ ០០០ | | ចំនួនបទសំភាសដែលបានបន្តផ្សព្វផ្សាយតាមស្ថានីយ៍ខេត្តក្រុង | |
| ផ្សាយបន្តការសំភាសន៍តាមវិទ្យុជាតិនៅទូទាំងប្រទេស | ៦០ ០០០ | | ចំនួនបទសំភាសន៍ដែលបានបន្តចាក់ផ្សាយតាមវិទ្យុ និង ចំនួន និង ទស្សនៈប្រជាជនដែលស្តាប់ការផ្សាយ | ៥០ភាគរយនៃព័ត៌មានប្រចាំថ្ងៃបានបញ្ចូលសារអំពីយេនឌ័រ |
| បញ្ចូលសារអំពីយេនឌ័រក្នុងការផ្សព្វផ្សាយព័ត៌មានប្រចាំថ្ងៃ | ៣០ ០០០ | | ចំនួន និង របាយការណ៍នៃការផ្សព្វផ្សាយព័ត៌មានដែលបានបញ្ចូលយេនឌ័រ | រាល់ទិវាសិទ្ធិនារី ៨ មិនាបានបញ្ចូលប្រធានបទយេនឌ័រ |
| រៀបចំសកម្មភាពលើកកំពស់យេនឌ័រស្របតាមប្រធានបទនានានៃទិវាអន្តរជាតិនារី ៨ មិនា | ១៥ ០០០ | | បណ្តាសកម្មភាពលើកកំពស់យេនឌ័រត្រូវបានអនុវត្តនាទិវាបុណ្យនារី ៨ មិនា | |

| យុទ្ធសាស្ត្រទី២: បង្កើនការយល់ដឹងអំពីយេនឌ័រទៅក្នុងវិស័យព័ត៌មានតាមគ្រប់លំដាប់ថ្នាក់ | | | | |
|---|---|---|---|---|
| សកម្មភាព | ថវិកាគិតជាដុល្លារ | អ្នកអនុវត្ត | សូចនាករ | ចំណុចដៅឆ្នាំ ២០១០ |
| ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេស ក្នុងការសំរបសំរួលវគ្គដោយមានការចូលរួម (participatory training) ដល់ក្រុមការងារយេនឌ័រនៅក្រសួងព័ត៌មាន | ៤៨០០ | ក្រុមការងារបញ្ជ្រាបយេនឌ័រ និង មន្ត្រីនៃក្រសួងព័ត៌មាន និង ស្ថាប័នទាក់ទិន | ចំនួនសិក្ខាកាម និង របាយការណ៍នៃវគ្គ បណ្តុះបណ្តាលដែលបានរៀបចំ | ក្រុមការងារបញ្ជ្រាបយេនឌ័រមានជំនាញ និង បទពិសោធន៍គ្រប់គ្រាន់ក្នុងការសំរបសំរួលវគ្គបណ្តុះបណ្តាលដោយមានការចូលរួម |
| ផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់ មន្ត្រីក្រសួងព័ត៌មាននៅថ្នាក់ជាតិ និង ខេត្ត-ក្រុង ⁹ | ១០៩០០ | ក្រុមការងារបញ្ជ្រាបយេនឌ័រ និង មន្ត្រីនៃក្រសួងព័ត៌មាន | ចំនួនសិក្ខាកាម និង របាយការណ៍នៃវគ្គ បណ្តុះបណ្តាលដែលបានរៀបចំ | ១០០ ភាគរយនៃថ្នាក់ដឹកនាំនៅថ្នាក់សមាជិករាជរដ្ឋាភិបាល អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរខេត្ត-ក្រុង និង ការិយាល័យ បានទទួលការបណ្តុះបណ្តាល អំពីយេនឌ័រ |
| ផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់បណ្តាញអ្នកសារព័ត៌មាន និង ពិធីករ | ២០៩០០ | ក្រុមការងារបញ្ជ្រាបយេនឌ័រ និង មន្ត្រីនៃក្រសួងព័ត៌មាន | ចំនួនសិក្ខាកាម និង របាយការណ៍នៃវគ្គ បណ្តុះបណ្តាលដែលបានរៀបចំ | ៥០ ភាគរយនៃអ្នកសារព័ត៌មាន និង ពិធីករ បានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ |
| បញ្ចូលប្រធានបទយេនឌ័រទៅក្នុងវគ្គបណ្តុះបណ្តាលនានារបស់ក្រសួងព័ត៌មាន | ១០ 000 | ក្រុមការងារបញ្ជ្រាបយេនឌ័រ និង មន្ត្រីនៃក្រសួងព័ត៌មាន | ប្រភេទប្រធានបទអំពីយេនឌ័របានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាល | ៥០ ភាគរយនៃវគ្គបណ្តុះបណ្តាលរបស់ក្រសួង ព័ត៌មានបានបញ្ចូលប្រធានបទអំពីយេនឌ័រ |
| យុទ្ធសាស្ត្រទី ៣: បញ្ចូលទិន្នន័យ សូចនាករ និង អ្នកទទួលផលប្រយោជន៍ដោយបែងចែកពីភេទទៅក្នុង ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន | | | | |
| បញ្ចូនសមបញ្ចូលសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រទៅក្នុងក្រុមរៀបចំផែនការប្រតិបត្តិរបស់ក្រសួង ព័ត៌មាន | ១០ 000 | ក្រុមការងារបច្ចេកទេសយេន ឌ័រ និង នាយកដ្ឋានផែនការ | របាយការណ៍ពិពណ៌នាពីភាពខុសគ្នារវាងបុរសនិងស្ត្រីក្នុងការទទួលសេវាព័ត៌មានអំពីយេនឌ័រនៅតាមទីក្រុងនិង ទីជនបទ | ១០០ ភាគរយនៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មានឆ្លើយតបទៅនឹងតំរូវការយេនឌ័រ |
| បណ្តុះបណ្តាលក្រុមការងារពីការរៀបចំផែនការឆ្លើយតបនឹងយេនឌ័រ | ៥000 | ធនធានក្រៅ | ក្រុមការងារទទួលការបណ្តុះបណ្តាល | ក្រុមការងារមានជំនាញ និង សមត្ថភាពការរៀបចំផែនការឆ្លើយតបនឹងយេនឌ័រ |
| ដាក់បញ្ចូលទិន្នន័យ សូចនាករនិងអ្នកទទួលផល ប្រយោជន៍ដោយបែងចែកពីភេទដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាង បុរស និង ស្ត្រីផ្នែកតំរូវការផ្នែកព័ត៌មានទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងព័ត៌មាន | ១០ 000 | ក្រុមការងារបច្ចេកទេសយេន ឌ័រ និង នាយកដ្ឋានផែនការ | ទិន្នន័យដែលមានការបែងចែកតាមភេទអំពីការទទួលសេវាព័ត៌មានត្រូវបានវិភាគ និងប្រើប្រាស់ | ១០០ ភាគរយនៃរបាយការណ៍និងទិន្នន័យនៃសេវាព័ត៌មានបានពិពណ៌នាអំពីភាពខុសគ្នារវាងបុរស និង ស្ត្រីក្នុងការទទួលសេវាព័ត៌មាន |
| ដាក់បញ្ចូលសូចនាករដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងបុរសនិងស្ត្រីផ្នែកតំរូវការផ្នែកព័ត៌មានទៅក្នុងការធ្វើជំរឿនប្រជាជនឆ្នាំ២០០៨ | | ក្រុមការងារបច្ចេកទេសយេន ឌ័រ និង ក្រសួងផែនការ | សូចនាករឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងបុរសនិងស្ត្រីពីតំរូវ ការ បញ្ហា ទស្សនៈអំពីគុណភាពនៃសេវា ព័ត៌មាន ការផ្តល់សេវាព័ត៌មាន ការទទួលសេវាព័ត៌មានត្រូវបានបញ្ចូលក្នុងរាល់ការស្រាវជ្រាវ និង ការធ្វើជំរឿនប្រជាជនឆ្នាំ ២០០៨ របស់ក្រសួងផែនការ | ១០០ ភាគរយនៃការអង្កេតស្រាវជ្រាវរបស់ក្រសួងព័ត៌មាន និងស្ថាប័នផ្សេងៗបានពិនិត្យលើតំរូវការ និង ទស្សនៈរវាង ស្ត្រី និង បុរសអំពីគុណភាព និង ការទទួលសេវាព័ត៌មាន |

| យុទ្ធសាស្ត្រទី ៤: បង្កើនចំណេះដឹង ជំនាញ សមត្ថភាព និង ទំនុកចិត្តរបស់មន្ត្រីព័ត៌មានជាស្ត្រីតាមរយៈការបង្កើនការចូលរួមរបស់មន្ត្រីព័ត៌មានជាស្ត្រីនៅក្នុងវគ្គបណ្តុះបណ្តាលទាំងក្នុង និង ក្រៅប្រទេស | | | | |
|---|---|---|---|---|
| សកម្មភាព | ថវិកាគិតជាដុល្លារ | អ្នកអនុវត្ត | សូចនាករ | ចំណុចដៅឆ្នាំ ២០១០ |
| បង្កើតនិតិវិធីអនុគ្រោះដើម្បីបង្កើនចំនួនមន្ត្រីព័ត៌មានជាស្ត្រីអោយទទួលបានការបណ្តុះបណ្តាលបន្ត | ១០ ០០០ | មន្ត្រីទទួលបន្ទុកធនធាន មនុស្សនៃក្រសួងព័ត៌មាន និង ថ្នាក់ដឹកនាំក្រសួងព័ត៌មាន | និតិវិធីអនុគ្រោះដើម្បីអោយមន្ត្រីព័ត៌មានជា ស្ត្រីទទួលបានការបណ្តុះបណ្តាលផ្សេងៗត្រូវ បានបង្កើត | ៣០ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលក្រៅស្រុក<br>១០ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីទទួលការបណ្តុះបណ្តាលក្នុងស្រុកយ៉ាងតិចបំផុត១ដងក្នុងរយៈពេល ១២ ខែ |
| ផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង គ្រប់គ្រង់ទាំងការបណ្តុះបណ្តាលរយៈ ពេលវែងនិងខ្លី និង ទាំងក្នុង និងក្រៅប្រទេសដល់មន្ត្រី ក្រសួងព័ត៌មានជាស្ត្រីដើម្បីបង្កើនចំណេះដឹង ជំនាញ សមត្ថភាព និង ទំនុកចិត្តក្នុងការងារ | ១០០ ០០០ | | របាយការណ៍ និង ចំនួនមន្ត្រីជាស្ត្រីដែលបានទទួលការបណ្តុះបណ្តាលរយៈពេលវែង និង ខ្លី និង ទាំងក្នុង និង ក្រៅ ប្រទេស | ៥ ភាគរយនៃមន្ត្រីក្រសួងព័ត៌មានជាស្ត្រីទទួលការបណ្តុះបណ្តាលនៅបរទេសយ៉ាងតិចបំផុតមួយដង ក្នុងរយៈពេល ១២ ខែ ទៅតាមតំរូវការម្ចាស់ជំនួយ<br>១០០ ភាគរយនៃក្រុមការងារបច្ចេកទេសយេនឌ័របានទទួលការបណ្តុះបណ្តាលក្នុងការប្រមូល និង វិភាគទិន្នន័យដែលឆ្លុះបញ្ចាំងពីយេនឌ័រ<br>រាល់ការជ្រើសរើសមន្ត្រីព័ត៌មាន ថ្មីបេក្ខនារីត្រូវបានលើកកំពស់ |
| សំរបសំរួលជាមួយបណ្តាស្ថាប័នរដ្ឋាភិបាល, ស្ថាប័នម្ចាស់ជំនួយ និងអង្គការនានាដើម្បីផ្តល់នូវការគាំទ្រលើល័ក្ខខ័ណ្ឌ អនុគ្រោះចំពោះមន្ត្រីព័ត៌មានជាស្ត្រី | ១០ ០០០ | មន្ត្រីទទួលបន្ទុកធនធាន មនុស្សនៃក្រសួងព័ត៌មាន និង ថ្នាក់ដឹកនាំក្រសួងព័ត៌មាន | របាយការណ៍នៃការសហការជាមួយស្ថាប័នរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និង អង្គការនានា ដែលបានផ្តល់ការគាំទ្រលើល័ក្ខខ័ណ្ឌ អនុគ្រោះ ចំពោះមន្ត្រីព័ត៌មានជាស្ត្រី | |
| យុទ្ធសាស្ត្រទី៥: ផ្តល់ឱកាស ការលើកទឹកចិត្ត និង លក្ខខណ្ឌអំណោយផលដល់មន្ត្រីព័ត៌មានជាស្ត្រីក្នុងការទទួលបានតួនាទីធ្វើសេចក្តីសំរេច ដើម្បីកាត់បន្ថយគំលាតរវាងមន្ត្រីព័ត៌មានជាបុរស និង ស្ត្រីក្នុងការធ្វើការសំរេច | | | | |
| បង្កើតនិតិវិធីនៃការតែងតាំងមន្ត្រីព័ត៌មានជាស្ត្រីសំរបសំរួល អោយមានការតែងតាំង និងតំឡើងតួនាទីដោយផ្អែកលើសមត្ថភាព និង គុណភាពការងារ | ១០ ០០០<br>១០ ០០០ | រដ្ឋាភិបាល និង ថ្នាក់ដឹកនាំ ក្រសួងព័ត៌មានដោយសហ ការជាមួយក្រុមការងារ យេនឌ័រនៃក្រសួង | និតិវិធីនៃការតែងតាំង និង សេចក្តីពិពណ៌នាការងារត្រូវបានបង្កើត | មន្ត្រីព័ត៌មានជាស្ត្រីចំនួន២៥ ភាគរយទទួលតំណែងប្រធាន និង អនុប្រធាន អគ្គនាយកដ្ឋាន, នាយកដ្ឋាន |
| បង្កើនមន្ត្រីព័ត៌មានជាស្ត្រីទទួលតួនាទីជាសមាជិករាជរដ្ឋាភិបាល ប្រធាន ឬ អនុប្រធាន អគ្គនាយកដ្ឋាន, នាយក ដ្ឋាន, មន្ទីរខេត្ត-ក្រុង និង ការិយាល័យ | | រដ្ឋាភិបាល និង ថ្នាក់ដឹកនាំ ក្រសួងព័ត៌មានដោយសហ ការជាមួយក្រុមការងារ យេនឌ័រនៃក្រសួង | ចំនួននិងភាគរយមន្ត្រីព័ត៌មានជាស្ត្រីដែលបានទទួលតំណែងជាប្រធាន ឬ អនុប្រធាន អគ្គនាយកដ្ឋាន, នាយកដ្ឋាន, មន្ទីរខេត្ត-ក្រុង និង ការិយាល័យ | មន្ត្រីព័ត៌មានជាស្ត្រីចំនួន ៣០ភាគរយ ទទួលតំណែងជាប្រធាន និង អនុប្រធានមន្ទីរព័ត៌មាន និង ថ្នាក់ការិយាល័យ ខេត្ត-ក្រុង |
| ជ្រើសរើសមន្ត្រីព័ត៌មានថ្មីត្រូវអោយមានសមាមាត្រស្មើគ្នារវាងបុរស និង ស្ត្រី | | ថ្នាក់ដឹកនាំក្រសួងព័ត៌មាន ដោយសហការជាមួយក្រុម ការងារ យេនឌ័រនៃក្រសួង | របាយការណ៍នៃការជ្រើសរើស និង ចំនួនមន្ត្រី ព័ត៌មានជាស្ត្រី និង បុរសដែលចូលបំរើការថ្មី | រាល់ការជ្រើសរើសមន្ត្រីព័ត៌មានថ្មីត្រូវមានសមាមាត្រស្មើគ្នារវាងបុរស និង ស្ត្រី |

| យុទ្ធសាស្ត្រទី៦: ធ្វើការតាមដាន និង វាយតំលៃរាល់កម្មវិធី និង សកម្មភាពរបស់ក្រសួងព័ត៌មាន ដើម្បីធានាថារាល់កម្មវិធី និង សកម្មភាពមានការឆ្លើយតបនិងគាំទ្រការយេនឌ័រ | | | | |
|---|---|---|---|---|
| **សកម្មភាព** | **ថវិកាគិតជាដុល្លារ** | **អ្នកអនុវត្ត** | **សូចនាករ** | **ចំណុចដៅឆ្នាំ ២០១០** |
| ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារយេនឌ័រក្នុងការវិភាគទិន្នន័យរៀបចំផែនការ តាមដាន និង វាយតំលៃកម្មវិធីព័ត៌មានដែលឆ្លើយតប និង យេនឌ័រ | ១៥ ០០០ | ស្ថាប័នជំនាញដែលអាចផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមការងារបញ្ជ្រាបយេនឌ័រ | ចំនួនសមាជិកក្រុមការងារយេនឌ័របានចូលរួមវគ្គបណ្តុះបណ្តាលអំពីការវិភាគយេនឌ័រ ការរៀបចំផែនការ ការតាមដាននិងវាយតំលៃកម្មវិធីព័ត៌មានដែលឆ្លើយតបនិងយេនឌ័រ | គ្រប់សមាជិកក្រុមការងារយេនឌ័រមានសមត្ថភាព និងជំនាញគ្រប់គ្រាន់ក្នុងការវិភាគ ការរៀបចំផែនការនិងតាមដាន និង វាយតំលៃកម្មវិធី ដែលឆ្លើយតប នឹងយេនឌ័រ |
| រៀបចំ និង ពិនិត្យរបាយការណ៍នៃសេវាព័ត៌មានឆ្លើយតបនិងយេនឌ័រ | ៥ ០០០ | សមាជិកក្រុមការងារបញ្ជ្រាបយេនឌ័រ និង នាយកដ្ឋានស្ថិតិ និងផែនការនៃក្រសួងព័ត៌មាន | ចំនួនរបាយការណ៍ព័ត៌មានដែលពិពណ៌នាអំពីបុរស និង ស្ត្រីបានទទួលផលពីកម្មវិធីព័ត៌មាន | គ្រប់របាយការណ៍ព័ត៌មានពិពណ៌នាអំពីបុរស និងស្ត្រីបានទទួលផលពីកម្មវិធីព័ត៌មាន |
| ពិនិត្យការអនុវត្តដោយជោគជ័យនូវសូចនាករ ដែលកំណត់ខាងលើ | | | ការសំរេចបាននូវសូចនាករ ដែលបានរៀបរាប់ខាងលើដោយជោគជ័យ | សូចនាករខាងលើបានសំរេចដោយជោគជ័យ |
| វាយតំលៃប្រសិទ្ធភាពនៃកម្មវិធីការសំភាសន៍អំពីយេនឌ័រតាមទូរទស្សន៍ និង វិទ្យុជាតិនិង ការបណ្តុះបណ្តាលអំពីយេនឌ័រក្នុងវិស័យព័ត៌មាន | ១០០ ០០០ | សមាជិកក្រុមការងារបញ្ជ្រាបយេនឌ័រ និង ស្ថាប័នពាក់ព័ន្ធ | របាយការណ៍នៃការវាយតំលៃដែលមានសារសំខាន់ដល់ការងារបញ្ជ្រាបយេនឌ័រ | បទសំភាសន៍ឆ្លើយតបនឹងតំរូវការ និង ផ្តល់ព័ត៌មានចាំបាច់សំរាប់ស្ត្រី និង បុរសក្នុងវិស័យនានា |

| **សរុប** | **៩៤៣៧០០ ដុល្លារ**<br>**ប្រាំបួនសែន បួនម៉ឺន បីពាន់ ប្រាំពីររយ ដុល្លារ** |
|---|---|

## ខ. ឯកសារយោង


European Commission (2004). Toolkit on Mainstreaming Gender Equality in EC Development Cooperation. Brussels, European Communities.

Ministry of Planning (2000). Cambodia Demographic and Health Survey. Phnom Penh, Ministry of Planning.

Ministry of Women's Affairs (2003). Five-Year Strategic Plan, Neary Rathanak. Phnom Penh, Ministry of Women's Affairs.

Ministry of Information (2006a). Annual Congress and Annual Planning for 2006. Phnom Penh, Ministry of Information.

Ministry of Information (2006b). Compiled Statistics on Staff Position, Education and Training. Phnom Penh, Ministry of Information.

Ministry of Planning (2006). National Strategic Development Plan, 2006-2010. Phnom Penh, Ministry of Planning.

Ministry of Health (2006). Gender Mainstreaming Action Plan for Health Sector. Phnom Penh, Cambodia.

Ministry of Women's Affairs, GTZ, UNIFEM, USAID, CIDA and East-West Management Institute (2006). Violence Against Women: A Baseline Survey. Phnom Penh, Ministry of Women's Affairs.

UNFEM, World Bank, ADB, UNDP and DFID/UK (2004). A Fair Share for Women, Cambodia Gender Assessment. Phnom Penh, United Nations Development Fund for Women East and Southeast Asia Regional Office, the World Bank, the Asian Development Bank, United Nations Development Programme and the Department of Foreign Affairs for International Development of the United Kingdom.

Women' s Media Centre of Cambodia (2005). Women and the Media in Cambodia, National Survey. Phnom Penh, Women' s Media Centre of Cambodia.

## គ. សមាជិកភាពក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងព័ត៌មាន

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

លេខ [illegible] ព.ម.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែ[illegible] ឆ្នាំ២០០៦

# ប្រកាស
## ស្តីពី
## ការកែសំរួលរចនាសម្ព័ន្ធ ក្រុមការងារបច្ចេកទេស យេនឌ័រ ក្រសួងព័ត៌មាន

## រដ្ឋមន្ត្រី ក្រសួងព័ត៌មាន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស រកម ០១៩៦ ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោង ប្រកាសលេខ ០៥៧ ផក ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ ២០០៥ ស្តីពីការបង្កើត ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន សំរាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ៥ឆ្នាំលើកទី ៣ ( ២០០៦-២០១០ ) របស់ក្រសួងផែនការ
- យោង ប្រកាសលេខ ៣៦៦/០៥ ព.ម ប្រក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥
- យោង តាមសំណូមពរ និង តម្រូវការចាំបាច់ ដើម្បីជំរុញការអនុវត្តន៍យុទ្ធសាស្ត្រ យេនឌ័រ
- ពិនិត្យលើសមត្ថភាព និងលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ

## សម្រេច

**ប្រការ១** : កែសំរួលរចនាសម្ព័ន្ធក្រុមការងារបច្ចេកទេសយេនឌ័រ (Gender) របស់ក្រសួងពត៌មាន ដែលមានសមាសភាព ដូចខាងក្រោម ÷

១- ឯកឧត្តម ខាត់ ឌីន រដ្ឋលេខាធិការក្រសួងពត៌មាននិងជាសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាប្រធាន

| | | |
|---|---|---|
| ២. លោកស្រី ខាវ ឧស្សីន | អគ្គនាយករងវិទ្យុជាតិកម្ពុជា | អនុប្រធានទី១ |
| ៣. លោកស្រី ចំន្ទ ធី | អគ្គនាយករងទូរទស្សន៍ជាតិកម្ពុជា | អនុប្រធាន |
| ៤. លោក ភឿន សម្បត្តិ | អនុប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៥. លោកស្រី រស់ សោភនី | អនុប្រធាននាយកដ្ឋាននៃ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ៦. លោក ម៉ក់ ទិដ្ឋៈ | អនុប្រធាននាយកដ្ឋាន (ជំនួយការ) | សមាជិក |
| ៧. លោកស្រី ទ្រាត់ អេលីសាវ | អនុប្រធានការិយាល័យ ទីភ្នាក់ងារសារពត៌មានកម្ពុជា AKP | សមាជិក |

**ប្រការ២** : ក្រុមការងារបច្ចេកទេសយេនឌ័រ មានភារកិច្ចដូចតទៅ ÷

- សម្របសម្រួលសហការ និងស្វែងរកការគាំទ្រថវិកា បច្ចេកទេស ពីស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិ ដើម្បីលើកកំពស់ការងារ យេនឌ័រ របស់ក្រសួងពត៌មាន ។
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹង ផ្នែកយេនឌ័ររបស់ក្រសួងពត៌មាន នៅថ្នាក់កណ្តាល បណ្តាខេត្ត-ក្រុង និងមូលដ្ឋាន ។
- ធ្វើផែនការ សកម្មភាពដែលពាក់ព័ន្ធ និងការងារប្រចាំឆ្នាំ ( ផែនការសកម្មភាព យេនឌ័រ នេះ គឺជាផ្នែកមួយ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ លើកទី ៣ ឆ្នាំ ២០០៦-២០១០ ) ។
- បញ្ជ្រាបទស្សនៈ យេនឌ័រ ទៅក្នុងគ្រប់កម្មវិធីរបស់ក្រសួងពត៌មាន ។
- ត្រួតពិនិត្យ និងវាយតំលៃរាល់សកម្មភាពការងារដែលបានអនុវត្ត ពាក់ព័ន្ធនឹងការងារ យេនឌ័រ ។

**ប្រការ៣** : ឯកឧត្តម លោកស្រី លោក ដែលមានឈ្មោះក្នុងក្រុមការងារខាងលើ ត្រូវបំពេញភារកិច្ចនេះបន្ថែមលើតួនាទីដែលមានកន្លងមក ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល-សោតទស្សន៍ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ខុទ្ទកាល័យ និងសាមីខ្លួនដូចក្នុងប្រការ១ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងពត៌មាន**

ខៀវ កាញារីទ្ធ

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកិច្ចការនារី

" **ដើម្បីជូនជ្រាប** "

- ដូចប្រការ ៤

" **ដើម្បីអនុវត្ត** "

- ឯកសារ